សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
Free Copies
Email:Khmerpostusa@gmail.com
www.khmerpostusa.com
Vol. 15. Issue 354, Sept 08, 2023 | Direct: 978-656-8141
Lowell - Lynn - Revere - MA * Providence - Cranston - RI

# ខ្មែរមាននាយករដ្ឋមន្ត្រីថ្មី តែបាតុករខ្មែរនៅប្រទេសបារាំងមិនស្វាគមន៍ទេ

ក្រុមបាតុករខ្មែរនៅអឺរ៉ុប បានមកជួបជុំគ្នានៅស្តួប«ឡាបាស្ទីយ»កណ្តាលក្រុងប៉ារីស កាលពីខែកក្កដាមុននេះ ដើម្បីទាមទារឲ្យរដ្ឋាភិបាលខ្មែរ គោរពសន្ធិសញ្ញាក្រុងប៉ារីសឆ្នាំ១៩៩១នៅពេលដែលគេបានដឹងថា ការបោះឆ្នោតសភាជាតិនៅកម្ពុជា អាណត្តិទី៧ បានក្លាយទៅជានៅក្រោមឥទ្ធិពលនាយករដ្ឋមន្ត្រី ហ៊ុន សែន ទាំងស្រុងដដែលទៅហើយនោះ។ បាតុករដដែលនោះដូចគ្នានឹងនៅកម្ពុជាដែរ ធ្លាប់បានទាមទារឲ្យប្តូរនាយករដ្ឋមន្ត្រីខ្មែរ ឲ្យមាននាយករដ្ឋមន្ត្រីថ្មី ឲ្យដូចប្រទេសប្រជាធិបតេយ្យឯទៀតៗ ប៉ុន្តែនាយករដ្ឋមន្ត្រីចាស់នៃគណបក្សប្រជាជននោះ ដែលកាន់

តទៅទំព័រទី០៣

## Kick Boxsing Kun khmerAt Lowell

WCK is bring world class Kun Khmer fighters to the Lowell Memorial Auditorium on September 30th to compete in an International Showdown of fighting.

With support from legendary Cambodian trainers Srab Sroeuy (Seattle) and Oum Ry (Long Beach), this event will showcase 10+ fights headlined by Sovenkesa Som and Preston Sroeuy.

Tickets start at $45 and are available at the Lowell Memorial Auditorium.
box office or on line.



PHOTO CAPTION: Promoter, Dennis Warner is congratulated by Lowell Mayor, the honorable Sokhary Chau for bringing Kun Khmer fighting to the city.

## ប្រកួតគុណខ្មែរនៅឡូវែល

WCK នឹងនាំអ្នកប្រដាល់គុនខ្មែរលំដាប់ពិភពលោក មកកាន់សង្វៀន Lowell Memorial នៅថ្ងៃទី៣០ ខែកញ្ញា ដើម្បីប្រកួតក្នុងកម្មវិធីប្រដាល់អន្តរជាតិ។

ដោយមានការគាំទ្រពីគ្រូបង្វឹកជើងខ្លាំងកម្ពុជា លោក ស្រិប ស្រឿយ (Seattle) និង អ៊ុំរី (Long Beach ) ព្រឹត្តិការណ៍នេះនឹងបង្ហាញការប្រកួតចំនួន ១០+ ដណ្តើមខ្សែក្រវ៉ាត់ Sovenkesa Som និង Preston Sroeuy។

សំបុត្រមានតម្លៃចាប់ពី ៤៥ ដុល្លារ ហើយអាចរកបាននៅ Lowell Memorial Auditorium តាមប្រអប់សំបុត្រ ឬតាមអនឡាញ។

រូបថត៖អ្នកផ្សព្វផ្សាយ លោក Dennis Warner ត្រូវបានអបអរសាទរ ដោយលោក សុខារី ចៅ អភិបាលក្រុងឡូវែល ដែលបាននាំយកគុនខ្មែរមកទីក្រុង៕






មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL
សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987
Excellent Service Since 1987
គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា
សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបំរើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ
Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense
Thank you for your continued confidence
In our office to handle your legal and tax matters.
We look forward to serving you well into the future.
LAW OFFICE OF LOUIS S. HASKELL * 16 PINE STREET * LOWELL, MA * (978) 459-8359
16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# New Cambodian Prime Minister but Old Politic

World News From Europe
* September 3, 2023

1. Cambodia has a new Prime Minister, but Cambodian protesters in France do not welcome *

Cambodian protesters in Europe gathered at the La Bastille in central Paris last July to demand that the Cambodian government abide by the 1991 Paris Peace Accords when it was learned that the seventh term of the Cambodian parliamentary election has become completely under the influence of Prime Minister Hun Sen. Similarly, the protesters in Cambodia had demanded the replacement of the Cambodian prime minister with a new one, as in other democratic countries, but the former CPP prime minister, who has been in power for 38 years, has sought to exert influence to let children to replace their fathers on 22 August 2023. Nieces and nephews of other senior CPP officials came to replace their fathers. The new cabinet consists of more than 500 officials - prime ministers, secretaries of state, undersecretaries of state, a vast majority in exchange for jealousy within the CPP and will reward those who defect from the opposition.

At the same time, the National Assembly held it session where two parties attended, 123 members from CPP and 5-member from Royalist Party FUNCINPEC to elect a new National Assembly President. The highest honor went to H.E Khuon Sodary, the first woman to be speaker of the National Assembly in the seventh term of Cambodia. The two parties are all feudal parties, with both parties using the succession of dynastic power in the state.



Cambodian protesters in Paris  Europe Last July 2023

On the other hand, the opposition party was unable to face the ruling party, as the Candlelight Party was banned from registering to vote. The "National Unity Party" split from the Royalist Party, there was no propaganda that affected the ruling party, and there was no support from the former opposition CNRP. Furthermore, the intimidation of the opposition, no credible country observer was involved, so many skeptical elections, free world countries could not be considered it as a "democratic election."

At the end of August 2023, Kem Sokha, the former president of the Cambodia National Rescue Party, was sentenced by Hun Sen's court to 27 years in prison for treason, without being allowed to see anyone other than his own family.

Change of power raises the question of whether Cambodia will be able to escape the yoke of communist foreigners?

This question arises from the time under former Prime Minister Hun Sen, Cambodia has gone from neutral politics to a one-party, one-party dictatorship in line with China, and has been richly rewarded by China. Therefore, it can be easily concluded that Hun Sen's influence will push the control of the next generation to fall into the hands of the same communist regime as before. Hun Manet, the new Cambodian Prime Minister, has also expressed his gratitude to his father for taking over the post.

In addition to a passing on a position from father to son, Hun Manet became a statesman with no previous experience as a politician in the country or foreign affairs, and as military general. Hun Sen may think that "despite no experience but can manage the country as long as he obtains highest degree, that is enough". And if there is harm to his son's life, Hun Sen will return to office. Now Hun Sen must get the position of acting head of state and does not care whether the king agrees or not. It is a

**Please see /10**



អ្នកទិញផ្ទះលើកដំបូង *
ទទួលបានការបញ្ចុះតម្លៃ

$500 សម្រាប់ថ្លៃរៀបចំ
ប្រតិបត្តិការខ្ចីប្រាក់ទិញផ្ទះ

*យ៉ាងហោចណាស់បុគ្គលម្នាក់ ដែលមានឈ្មោះនៅក្នុងពាក្យសុំខ្ចីប្រាក់ទិញផ្ទះ ដែលមិនមានកម្មសិទ្ធិលើលំនៅដ្ឋានចម្បង ក្នុងរយៈពេលបីឆ្នាំមុន នៃការដាក់ពាក្យសុំខ្ចីប្រាក់ទិញផ្ទះ ត្រូវបានចាត់ទុកថាជាអ្នកទិញផ្ទះលើកដំបូង ។ កម្ចីទាំងអស់ គឺត្រូវមានការអនុម័តឥណទាន ។ ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ឱកាសពិសេសនេះ កម្ចីទាំងអស់ត្រូវតែដំណើរការនៅចំថ្ងៃ ឬក្រោយថ្ងៃទី 4/3/2023 ហើយត្រូវបិទបញ្ចប់ ត្រឹមថ្ងៃទី 12/29/2023 ។

Enterprise Bank

EnterpriseBanking.com/FTHB | 877-671-2265 | NMLS# 449369

Member FDIC

EQUAL HOUSING LENDER

តមកពីទំព័រទី ០៦

## ខ្មែរមាននាយករដ្ឋមន្ត្រីថ្មី តែបាតុករ

ដំណែងបាន៣៨ឆ្នាំហើយនោះ បានរៀបចំប្រើឥទ្ធិពលខ្លួន ដើម្បីឲ្យកូនបង្កើតខ្លួនចូលមកកាន់ដំណែងជំនួស កាលពីថ្ងៃទី២២សីហា២០២៣ កន្លងទៅ រួមទាំងឲ្យកូនខ្ទួយមន្ត្រី នៃគណបក្សប្រជាជនធំៗឯទៀត មកឡើងកាន់ដំណែងជំនួសឪពុកតែរៀងៗខ្លួន ថែមទៀតផង។ សមាជិកនៃគណរដ្ឋមន្ត្រីថ្មី មានឧបនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិកា ដល់ទៅជាង៥០០នាក់ ដែលជាចំនួនដ៏ច្រើនលើសលុប ជាថ្នូរនៃច្រណែនក្នុងគណបក្សប្រជាជន នឹងជារង្វាន់ដល់អ្នកដែលចុះចូលមកពីគណបក្សប្រឆាំងផងដែរ។

ស្របពេលជាមួយគ្នានោះក៏មានការប្រជុំសមាជិកសមាជិកាសភាថ្មី ហើយនៅក្នុងនោះ មានគណបក្ស២ចូលរួម គឺមកពីគណបក្សប្រជាជនមានសមាជិក១២៣រូប នឹងគណបក្សរាជានិយម ហ៊ុនស៊ិនប៉ិច មានសមាជិក៥រូម ក៏បានរជ្រើសតាំងប្រធានរដ្ឋសភាថ្មី ដំណែងដ៏ខ្ពង់ខ្ពស់នោះ បានទៅលោកជំទាវ ឃួន សុដារី ជាស្ត្រីទី១ ដែលទទួលបានដំណែងជាប្រធានរដ្ឋសភា ដំបូងគេបង្អស់នាអណត្តិទី៧នេះ នៅសភាជាតិកម្ពុជា ។ គណបក្សទាំង២ក្នុងសភាជាតិ អាណត្តិទី៧នេះ សុទ្ធសឹងជាគណបក្សមាននិន្នាការជាបេបសក្តិភូមិដោយទាំង២គណបក្សនោះ ប្រើការបន្តរដំណែងនៃអំណាចបន្តរពូជ ជាអំណាចក្នុងរដ្ឋ ។

ម្យ៉ាងវិញទៀត ខាងគណបក្សប្រឆាំងវិញ ពុំមានលទ្ធភាពនឹងប្រឈមមុខគណបក្សកាន់អំណាចបានទេ ដោយ

តទៅទំព័រទី១២



អតីតនាយករដ្ឋមន្ត្រី ហ៊ុន សែន(ជា ឪពុក) និងនាយករដ្ឋមន្ត្រីថ្មី ហ៊ុន ម៉ាណែត(ជាកូន)




បាតុកម្មសហគមន៍ខ្មែរនៅប៉ារីស អឺរ៉ុប កាលពីខែកក្កដា ២០២៣

## សង្គ្រាមនៅអ៊ុយក្រែន

យើងខកខានមិនបាននិយាយពីសង្គ្រាមនៅអ៊ុយក្រែន ២ខែហើយ យើងត្រឡប់មកវិញនាពេលនេះ ពីព្រោះមានការវិវត្តន៍សំខាន់ៗថ្មី ដែលគួររាយការ គឺ ទី១ មេទ័ពស្រួចស៊ីឈ្នួលដ៏ល្បីល្បាញរុស្ស៊ី ប្រេគោស៊ីន បានត្រូវរងការបាញ់ទម្លាក់យន្តហោះសម្លាប់ ដោយប្រធានាធិបតី ពូទីន ជាការដាក់ទណ្ឌកម្ម ពីបទហ៊ានលើកទ័ពចូលមកគម្រាម ក្រឹមឡាំង កាលពី៣ខែមុន ឥឡូវទ័ពដ៏ខ្លាំងរបស់រុស្ស៊ីបាត់បង់ កងទ័ពរុស្ស៊ីទាំងមូលត្រូវចុះអន់ថយ មានការខូចខាតយ៉ាងដំណំ ស្មើរគ្រប់សមរភូមិ បណ្តាលឲ្យកងទ័ពខាងអ៊ុយក្រែនវាយលុកចូលទីតាំងកាពារដោយរុស្ស៊ី ទោះជាទៅមុខយឺតៗក្តី តែបានមកវិញជាច្រើនកន្លែង ។ ទី២ ទិបញ្ហាការសហរដ្ឋអាមេរិក នឹងសម្ព័ន្ធមិត្រអូតង់ បានសម្តែងការរីករាយខ្លះៗមកវិញ បន្ទាប់ពីបានឃើញកងកម្លាំងប្រធានាធិបតី ជេឡិនស្គី វាយយកបាន អូរីគីវ នៅប៉ែកខាងត្បូង រួចវាយទម្លាយរនាំងកាពារដ៏រឹងមាំរបស់រុស្ស៊ី ចូលទៅដល់រ៉ូបូទីន កាន់កាប់តំបន់ក្បែរៗនោះ ហើយដោតទង់ជ័យអ៊ុយក្រែន នៅ២កន្លែងក្នុងតំបន់កាន់កាប់ដោយរុស្ស៊ីទៀត។ អ៊ុយក្រែននៅសម្តែងការមិនពេញចិត្ត ពិសម្ព័ន្ធមិត្រ ដែលមិនបានផ្តល់យន្តហោះប្រដេញ F16 មកឲ្យទ័ពខ្លួន ហេតុនោះហើយបានជាការវាយបកក្លាយជាយឺតយ៉ាវ។

អ្នកវិភាគ បានមើលឃើញ កម្លាំងទ័ពរុស្ស៊ី ទោះជាមានរបងកាពារដំបន់រំដោះរបស់ខ្លួនដ៏រឹងមាំយ៉ាងណាក្តី ក៏ហាក់ដូចជាធ្លាក់ដៃយ៉ាងច្រើន ប្រឈមមុខនឹងកងកម្លាំងអ៊ុយក្រែនៈ ស្លាប់ក៏ច្រើន បាក់ទ័ពក៏ច្រើន, នៅមានកងកម្លាំងបះបោររុស្ស៊ីក៏បង្កើនការប្រយុទ្ធរបស់ក្រុមខ្លួន នៅក្នុងប្រទេសរុស្ស៊ីជាច្រើនកន្លែងបានថែមទៀត ។ រួមគ្នានឹង យន្តហោះដ្រូន របស់អ៊ុយក្រែនបង្កើនការទម្លាក់គ្រាប់បែកធុនតូចៗ ច្រើនកន្លែងនៅទីក្រុងក្នុងដែនដីរុស្ស៊ី ធ្វើឲ្យប្រជាពលរដ្ឋរុស្ស៊ីលែងយល់ថា ជាសង្គ្រាមជាមួយ អ៊ុយក្រែន ពុំមែនតូចតាចដូចមុនទៀតហើយ។ នាវាសង្គ្រាមអ៊ុយក្រែន ក៏បានប្តើមល្បាតនៅតាមសមុទ្រខ្មៅ ដែលធ្លាប់ជាអំណាចរបស់រុស្ស៊ី ដោយមិនសូវព្រួយបារម្ភដូចមុន ហើយបានបញ្ជូនចេញគ្រាប់ធញ្ញជាតិតាមកុប៉ាល់ជំនួញ បាន២ជើងរួចហើយ ដោយគ្មានការគម្រាមកំហែង ពីនាវាល្បាតរុស្ស៊ីអ្វីទេ។ ស្ពានផ្លាប់ជ្រោយគ្រីមេ ទៅដែនដីរុស្ស៊ី បានត្រូវគម្រាមកំហែងដោយភេរវកម្មអ៊ុយក្រែនជាប្រចាំ ហើយទ័ព ជេឡិនស្គី បានប្តើមចូលវាយយកគ្រីមេ ជាលើកដំបូង ដោយមានការលើកទឹកចិត្តពីអាមេរិកនឹងអឺរ៉ុបទៀតផង។ ទទួលជំនួយពីអាមេរិកដោយខ្វះយន្តហោះប្រដេញ ហើយគ្មានក៏សិទ្ធយកអាវុធសង្គ្រាមរបស់



លោក ប្រេគោស៊ីន បានត្រូវសម្លាប់
ដោយប្រធានាធិបតី ពូទីន

ប្រទេសម្ចាស់ជំនួយ ទៅវាយក្នុងដែនដីរុស្ស៊ីទៀត បានធ្វើឲ្យកងកម្លាំង អ៊ុយក្រែន ចាញ់ប្រៀប រុស្ស៊ី យ៉ាងច្រើនអន្លើ តែអ៊ុយក្រែននៅតែវាយបកចូលច្រើនរយគីឡូម៉ែត្រ ចូលក្នុងប្រទេសរុស្ស៊ីបាន ដោយប្រើដ្រូនខ្លួនឯង ទៅទម្លាក់គ្រាប់បែក ធ្វើឲ្យខូចខាតបានច្រើនកន្លែង ជុំវិញក្រុងមូស្គូ។

ការបាត់បង់ទ័ពស្រួចស៊ីឈ្នួល ប្រេគោស៊ីនបានត្រូវជំនួសដោយទ័ពស៊ីឈ្នួលមួយទៀត គឺទ័ព ឈៀកឆេនី ដែលមានឈ្មោះល្បីណាស់ដែរ ហើយជាពិសេសនោះ កងទ័ពថ្មីបានសច្ចាថានឹងមានភាពស្មោះត្រង់ជានិច្ច ជាមួយលោកប្រធានាធិបតី ពូទីន ។ ចំណែកកងទ័ពប្រេគោស៊ីន មួយផ្នែកទៀត ច្រើនម៉ឺននាក់ មានវត្តមាននៅតំបន់អាហ្វ្រិកជាច្រើនកន្លែងនៅឡើយ ដែលធ្វើឲ្យអ្នកសង្កេតការជាច្រើន នៅយល់ថា មេទ័ពប្រេគោស៊ីន ទំនងជានៅរស់នៅឡើយទេ ៕

# តើអ្នកមានមើលថែទាំមនុស្សជាទីស្រឡាញ់នៅផ្ទះដែរឬទេ ?



# តាមរយៈកម្មវិធីថែទាំក្រុមគ្រួសារ

អ្នកអាចក្លាយជាអ្នកមើលថែទាំសមាជិកគ្រួសារគ្រប់វ័យដែលមានបញ្ហាដូចជាបញ្ហាខួរក្បាល បញ្ហានៃការលូតលាស់ ឬ បញ្ហាពិការផ្លូវកាយ ដែលធ្វើឱ្យសមាជិកគ្រួសាររបស់អ្នកត្រូវការការជួយថែទាំដើម្បីអាចនៅផ្ទះបានដោយមានសុវត្ថិភាព

## តើកម្មវិធីថែទាំសមាជិកគ្រួសារនេះអាចជួយអ្វីដល់អ្នកខ្លះ ?

យើងអាចផ្តល់ជូនអ្នកនិងមនុស្សជាទីស្រលាញ់របស់អ្នកនូវជំនួយ

- ដូចជាថវិកា
- អ្នកគ្រប់គ្រងសំណុំរឿង
- គិលានុបដ្ឋាយិកា

Nonotuck
Resource Associates, Inc.

Caregiving
With Love
https://www.nonotuck.com/khmer

ពីអឺរ៉ុប • ថ្ងៃទី៣កញ្ញា២០២៣

## ព័ត៌មានសំខាន់ៗក្នុងពិភពលោក

# រដ្ឋប្រហារនៅ"គ្នាបុង"ប្រទេស អាហ្វ្រិកកណ្តាល

កាលពីថ្ងៃទី៣០សីហានេះ នៅប្រទេសបុងគ្លោ មានរដ្ឋប្រហារមួយបានកើតឡើង ដោយឧត្តមសេនីយជាអង្គរក្សនៃលោកប្រធានាធិបតី បុងគ្លោ ហើយបានចាប់ប្រធានាធិបតីខ្លួនឯង ឲ្យជាប់ឃុំឃាំងនៅផ្ទះ ហើយ«ប្រកាសរួចមក ហើយនាឧកាសបោះឆ្នោតលើកនេះទៀត គឺមានចោទប្រកាន់ថាមានការលួចបន្លំសន្លឹកឆ្នោត ដើម្បីឲ្យប្រធានាធិបតីចាស់ មានការជាប់ឆ្នោតជាថ្មីម្តងទៀត គឺសម្រាប់ប្រធានាថិបតីបន្តរដំណែង ដូច្នេះហើយ បានជាមានការផ្ទុះរដ្ឋប្រហារ



ប្រធានាធិបតី បុងហ្គោ (រូបខាងឆ្វេង)រងរដ្ឋប្រហារដោយឧត្តមសេនីយ៍អង្គរក្ស(រូបខាងឆ្វេង) ដោយបុព្វហេតុគ្រួសារនិយម

លុបចោលលទ្ធផលនៃការបោះឆ្នោត» ដែលទើបនឹងប្រកាសប្រមាណ១៥នាទីមុនថា ប្រធានាធិបតី បុងគ្លោ បានឈ្នះគូរប្រគួតរបស់ខ្លួនបានជាង៦០%។ភ្លាមៗនោះ គេសង្កេតឃើញក្រុមធ្វើរដ្ឋប្រហារនោះ ហាក់ដូចជាមានប្រជាប្រិយភាពច្រើន ក្នុងចំណោមប្រជាពលរដ្ឋទិក្រុងនៅ គ្នាបុង នឹងទាំងប្រជាពលរដ្ឋគ្នាបុង ដែលភៀសខ្លួនមកនៅក្រៅប្រទេសជាច្រើនផងដែរ។ ពុំមានសញ្ញាណាថាមានការលូកដៃ ពីសំណាក់ ចិន ឬរុស្ស៊ី ដូចនៅប្រទេសអាហ្វ្រិកកណ្តាលទេ ។ ប្រទេសបារាំង ដែលជាដៃគូរអភិវឌ្ឍន៍យ៉ាងជិតស្និត ជាមួយប្រធានាធិបតី បុងគ្លោ ក៏ហាក់ដូចជាពុំមានការចោទប្រកាន់ណាមួយ ថាបារាំងមានការឃុបឃិត ជាមួយប្រធានាធិបិតី បុងគ្លោ ដែរ។ គេសង្កេតឃើញថា រដ្ឋប្រហារនោះ មានប្រជាប្រិយភាពក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ ក៏ព្រោះតែប្រធានាធិបតី អាលី បុងគ្លោ បានបន្តរអំណាច១៤ឆ្នាំមក ហើយ ពីឪពុករបស់ខ្លួន ឈ្មោះ អូម៉ា បុងគ្លោ ដែលបានកាន់អំណាច៤១ឆ្នាំមុន យោធា នៅចន្លោះពេលដែលគ្មានប្រធានាធិបតីថ្មី មកទទួលដំណែង។

ប្រទេស«គ្នាបុង»ជាប្រទេស ដែលកំពុងតែអភិវឌ្ឍន៍ដ៏សំខាន់មួយនៅអាហ្វ្រិក សម្បូរអណ្តូងរ៉ែ ដែលប្រទេសធំៗត្រូវការ មានទំនាក់ទំនងសេដ្ឋកិច្ចទៅបរទេស សមរម្យ ធ្វើឲ្យជីវភាពពលរដ្ឋឡើងខ្ពស់ ដែលអ្នកសង្កេតការយល់ថាជាទិដែលប្រទេសមហាអំណាច ដណ្តើមគ្នាដើម្បីទាញយកប្រយោជន៍រៀងៗខ្លួនជាមិនខាន។ ប្រទេសបារាំង តាំងតែពីដកអាណានិគមចេញប្រទេសទាំងឡាយនៅអាហ្វ្រិក នាឆ្នាំ១៩៥៥មក មិនបានចេញពីតំបន់នោះទេ តែនៅចងសម្ព័ន្ធសហការជាដៃគូរអភិវឌ្ឍន៍ រហូតមកដែរ ។

នៅថ្ងៃចន្ទខាងមុខ ឧត្តមសេនីយ ប្រីសង្វលិគីញ៉េម៉ានឹងធ្វើសច្ចាប្រណិធាន លើងកាន់ដំណែងជាប្រធានាធិបតីបណ្តោះអាសន្ន រីឯគណបក្សដែលចាញ់ឆ្នោតកាលពីសប្តាហ៍មុន ក៏ទាមទារថាខ្លួនជាអ្នកឈ្នះឆ្នោតឲ្យអ្នកកាន់អំណាចថ្មី រកយុត្តិធម៌ឲ្យខ្លួន៕

# រដ្ឋប្រហារនៅប្រទេស"នីហ្សេរីយ៉ា"ប្រទេស អាហ្វ្រិកាខាងជើង ហៅតំបន់សាអែល

កាលពីខែកក្កដា មុននេះសោះ នៅប្រទេស«នីហ្សេរីយ៉ា» ឧត្តមសេនីយ ទីយ៉ានី អង្គរក្សរបស់ប្រធានាធិបតី ម៉ូហាមេត បាហ្សូម បានធ្វើរដ្ឋប្រហារ ចាប់ប្រធានាធិបតីរបស់ខ្លួនដាក់គុក ហើយប្រកាសកាន់អំណាចជំនួសក្នុងប្រទេសនីហ្សេរីយ៉ា ដោយខ្លួនឯង ភ្លាមដែរ កាលពិថ្ងៃទី.៣០កក្កដា២០២៣ កន្លងទៅ ។ រដ្ឋប្រហារនេះបានកើតឡើងពីអំពើពុករលួយ អសមត្ថភាព អសន្តិសុខ តែមានសញ្ញានៃការលើកទឹកចិត្តរបស់ប្រទេសរុស្សី នឹងក្រុមទាហ៊ានស៊ីឈ្នួលរុស្ស៊ី«វ៉ាកនែ» ដែលចង់ឲ្យទាហ៊ានឡើងកាន់អំណាចវិញ ដើម្បីភាពរុងរឿងវិញ នឹងមានការគាំទ្រ ដោយប្រទេសជិតខាងខ្លះទៀត ដូចជា ប្រទេសម៉ាលី ប៊ូគីណាហ្វាសូ នឹងគ្នីណេ ដែលចង់មានវាស្នាដូចគ្នា ក្នុងតំបន់សាអែល ។ ក៏ប៉ុន្តែ នៅក្នុងតំបន់ដូចការគម្រាមរបស់ក្រុមរដ្ឋប្រហារទេ» ។ស្ថានទូតប្រទេសបារាំង បានត្រូវឡោមព័ទដោយក្រុមបាតុករ ដែលទាមទារបណ្តេញឲ្យបារាំងដកចេញពីប្រទេសរបស់ខ្លួនតែទូតបារាំងមានកម្លាំងទ័ព១៥០០នាក់ មិនបានស្តាប់ពាក្យគម្រាមទាំងនោះនៅឡើយទេ ។

ប្រទេសបារាំង ដែលមានកម្លាំងទ័ពពង្រឹងជំហ៊រស្ថានទូតមែន ទោះជាបាន






ប្រទេសនៅតំបន់សាអែល ដែលរងរដ្ឋប្រហារ ស្រដៀងគ្នា នៅអាហ្វ្រិកកណ្តាល នារយៈពេល៣ឆ្នាំចុងក្រោយនេះ

ជិតខាងវិញ ដូចជាក្រុមប្រទេសសេដ្ឋកិច្ចអាហ្វ្រិក«សេដេអាអូ» ក៏មានប្រទេសប្រជាធិបតេយ្យ ហើយមិនគាំទ្ររដ្ឋប្រហារនោះដែរ ថ្វីត្បិតនៅក្នុងក្រុង ឧត្តមសេនីយ ទីយ៉ាមុី មានប្រជាពលរដ្ឋជាច្រើនធ្វើបាតុកម្មគាំទ្រ ឲ្យប្តូរប្រធានាធិបតីចាស់ចេញក៏ដោយ។ ប្រទេសបារាំង ដែលជាដៃគូរអភិវឌ្ឍន៍របស់នីហ្សេរីយ៉ា ក៏មិនបានគាំទ្ររដ្ឋប្រហារនោះដូចគ្នា ដោយថា «ប្រធានាធិបតីចាស់ឡើងកាន់អំណាចដោយការជាប់ឆ្នោតស្របច្បាប់ ហើយក្លាហានមិនព្រមលាលែងពីដំណែងប្រកាសមិនគាំទ្ររដ្ឋប្រហារក៏ដោយ ប៉ុន្តែ មិនដឹងជាអាចទ្រាំបានយូរប៉ុណ្ណានោះទេ សហរដ្ឋអាមេរីកក្តី ប្រទេសខ្លះនៅអឺរ៉ុបក្តី មិនសូវជាចាប់អារម្មនឹងរដ្ឋប្រហានោះទេ ថែមទាំងឃាត់បារាំងកុំឲ្យតឹងតែងពេក តែលោកប្រធានាធិបតីបារាំង ម៉ាក្រុង នៅតែមិនគាំទ្រក្រុមអ្នកធ្វើរដ្ឋប្រហារដដែល។

នៅមានប្រទេសនៃតំបន់សាអែលខ្លះទៀត ដែលត្រូវរំលំដោយរដ្ឋប្រហារយោធា បន្តរបន្ទាប់គ្នា នា៣ឆ្នាំចុងក្រោយនេះ ដូចរលំគ្រាប់ដូមីណូដែរ មានប្រទេស

# ស្គាល់ស្ដេចឆាលទី៣ នៃចក្រភព អង់គ្លេសដែរឬទេ ?

**ពីអឺរ៉ុប: ខែមិថុនា២០២៣**

នៅចក្រភពអង់គ្លេស ប្រទេសដ៏ល្បីល្បាញនឹងដ៏មានអំណាចក្នុងលោកមួយនេះ ទើបនឹងមានស្ដេចថ្មី គឺឆាលទី៣ បន្តរាជ្យពីម្ដាយ អេលិសាបេតទី២ ដែលបានសោយរាជ៧០ឆ្នាំ នៅលើចក្រភពអង់គ្លេស នឹងលើប្រទេស«ខម៉ន់វាល»។



រាជបុត្រ ឆាល ទទួលតំណែងជារាជទាយាទពី ព្រះមាតាមហាក្សត្រី អេលីហ្សាប៊ែត កាលពីជាង៥០ឆ្នាំមុន



ឆាល III ឡើងគ្រងរាជជាមួយព្រះមហេសី កាមេឡា ឆ្នាំ២០២៣

បើតាមរដ្ឋធម្មនុញ្ញ ស្ដេចថ្មីនេះ ឡើងកាន់អំណាច ចាប់តាំងពិថ្ងៃដែលគេប្រកាសថា ស្ដេចអង្គមុនបានចូលទីវង្គត់ភ្លាមមកម្លេះ គឺនៅថ្ងៃទី ៨វិច្ឆិកា២០២២ ប៉ុន្តែគេធ្វើពិធិអភិសេកឡើងគ្រងរាជ្យជាផ្លូវការ នៅថ្ងៃទី ៦មេសា២០២៣។

ស្ដេចឆាលទី៣នៃចក្រភពអង់គ្លេស ឡើងគ្រងរាជ្យនៅព្រះជន្ម ៧៣ ឆ្នាំ ក្នុងព្រះរាជពិធីស្របតាមទំនៀមទំលាប់រាជវង្ស យ៉ាងតឹងតែង ។ តាំងពីព្រលឹមថ្ងៃទី៥ឧសភានោះ ព្រះអង្គចេញដំណើរតាមរទេះសេះ ពីព្រះបរមរាជវាំង ប៊ើឃីងគ្ហាំ ទៅកាន់ព្រះវិហារ វែសមិនស្ទើនាទិក្រុងឡុង។ នៅទីនោះ ព្រះអង្គបានដាក់ព្រះហស្តលើសៀវភៅ បាយប៊ីល ហើយធ្វើសច្ចាប្រណីធាន នៅចំពោះព្រះភក្ត្រព្រះ បន្ទាប់មកទើបមានការប្រគល់ដំបងរាជ្យនឹងបំពាក់មកុដរាជ្យថ្វាយព្រះអង្គ នឹងបំពាក់មកុដថ្វាយមហាក្សត្រីយានីយ ផងដែរ។ ព្រះរាជពិធីនៅឯវិហ៊ារ អស់រយៈពេល២ម៉ោងទើបចប់ ទើបព្រះអង្គយាងប្រថាប់ក្នុងរទេះសេះជាមួយព្រះជាយា ត្រឡប់មកកាន់ព្រះបរមរាជវាំងវិញ ដោយគាត់តាមទិក្រុង ដែលមានប្រជាពលរដ្ឋរង់ចាំទទួលអបអរស្ដេចថ្មី នាដងផ្លូវនៃទីក្រុងឡុងជាច្រើនម៉ឺនសែននាក់៕ មកដល់ព្រះបរមរាជវាំងហើយព្រះអង្គនឹងព្រះរាជវង្សទាំងមូល ចេញមកបង្ហាញខ្លួនម្ដងទៀតដល់ប្រជារាស្ត្រព្រះអង្គនៅបង្កាន់ដៃនៃប្រសាទ ប៊ើឃីងគ្ហាំ តាមប្រពៃណីរបស់រាជវង្សថ្មី។

បើតាមរដ្ឋធម្មនុញ្ញឬបស់អង់គ្លេស នៅពេលដែលស្ដេច ឆាលទី៣ ចូលទិវង្គត់ទៅ នឹងមានព្រះអង្គម្ចាស់ វីលាមជាព្រះរាជបុត្រច្បងដែលជារាជទាយាទនឹងឡើងគ្រងរាជ្យបន្តរ មិនមែនបន្តរទៅ



រាជទាយាទ ឆាល មានមហេសីមុន ព្រះនាម ដៃយ៉ាណា (ស្លាប់ដោយគ្រោះថ្នាក់រថយន្ត)

ព្រះមហាក្សត្រីយានីយ កាម៉េឡា ទេ ។

ស្ដេចឆាលទី៣ ជានរណា?

កើតនៅថ្ងៃទី១៤ខែវិច្ឆិកាឆ្នាំ១៩៤៨ នៅវិមានប៊ឹឃិងគ្ហាំ នាទីក្រុងឡុង។ នៅពេលអាយុ៤ឆ្នាំ ព្រះមាតាអេលិសាបេតទី២ បានត្រូវឡើងគ្រងរាជ្យបន្តពីព្រះបីតាព្រះនាង ដែលបានចូលទីវង្គត់ ដូច្នេះព្រះរាជទាយាទបានធ្លាក់ទៅព្រះរាជបុត្រច្បង គឺទ្រង់ ឆាល ដែល

តទៅទំព័រទី១៩

# Do you know King Charles III of the United Kingdom?

**From Europe x June 2023**

In Britain, the world's most famous and powerful country has just coronated a new king, Charles III, earlier this month, succeeding his mother, Queen Elizabeth II, who ruled the country for 70 years. "Commonwealth." It is a huge event in the world because many other countries are involved, according to the constitution, the new king came to power since the day it was announced that the previous Queen died immediately on November 8, 2022, but the official coronation ceremony will take place on April 6, 2023.

Charles III of the United Kingdom ascended the throne at the age of 73 in a strict royal ceremony. On the morning of May 5, he set out in a horse-drawn carriage from Buckingham Palace to Westminster Temple in London. There he laid his hands on the Bible and swore an oath before the Anglican, then handed over the scepter and crown to the priest and crowned the queen. The ceremony at the temple lasted for two hours, after which he rode in a chariot with his wife back to the royal palace, as he followed the town where there were tens of thousands of people waiting to greet the new king on the streets of London.

Arriving at the Royal Palace, he and the entire royal family reappeared to his people again at the reception of the Buckingham Temple, in the tradition of the new dynasty of the United Kingdom.

According to the British Constitution, if at the time of the death of King Charles III, there would be Prince William, the eldest son, the heir to the throne, not to Queen Camella as queen.

Who is King Charles III?

Born November 14, 1948, at Buckingham Palace in London. When he was four years old, his mother, Elizabeth II, succeeded her father, who died, so the heir to his eldest son, Charles, ruled. "The heir to the Echelon country."

His father was Prince Philip, who was Dutch Edinburgh. Prince Charles, a naval officer, married his first wife, Princess Diana, and had two sons, Prince William, and Prince Harry, but later his wife, Camella, did not have a son.

If Prince William failed to the throne by any means, it was not Harry who succeeded him, but his eldest son William who would succeed him, this is the meaning of the British Constitution.

Which countries does King Charles III reign over?

Is not the only "United Kingdom"! the "Kingdom of Commonwealth" that there are four separate countries.

It should be noted that King Charles III succeeded Elizabeth II, who at the end of her life reigned as Queen of Great Britain (Britain, Wales, Northern Ireland, and Scotland), as Commonwealth. Other major countries, such as Australia, Canada, New Zealand and 14 other African countries, these countries recognized King Charles III as their head of state, such as the Bahamas, Antica and Barbuda or Belize. It should be noted that during the 70-year reign of

Please see /20

# បទពិសោធន៍រដូវកាលរដូវស្លឹកឈើជ្រុះ នៅក្រុងឡូវែល៖ ការប្រារព្ធពិធី និងព្រឹត្តិការណ៍តាំងលម្អភ្លើងដ៏អស្ចារ្យ នៅទីក្រុងឡូវែល

ទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០២៣ — ទីក្រុងឡូវែលកំពុងរៀបចំសម្រាប់រដូវកាលរដូវស្លឹកឈើជ្រុះដ៏អស្ចារ្យដែលពោរពេញទៅដោយការប្រារព្ធពិធី។ ចាប់ពីខែកញ្ញា ដល់ខែ វិច្ឆិកា ទីក្រុងឡូវែលនឹងភ្លឺត្រចះត្រចង់ជាមួយនឹងព្រឹត្តិការណ៍ និងពិធីបុណ្យជាច្រើន ធានាថានឹងទាក់ទាញទាំងអ្នកស្រុក និងអ្នកទស្សនា។

សូមស្វាគមន៍ទាំងអស់គ្នា ដើម្បីទទួលបានបទពិសោធន៍សប្បាយរីករាយជាលក្ខណៈគ្រួសាររៀបចំដោយសហគមន៍យ៉ាងកក់ក្តៅ និងរីកចម្រើនរបស់យើង។

ព្រឹត្តិការណ៍សំខាន់ៗ រួមមាន៖

- ពិធីបុណ្យ Our Lady of Loreto – ១-៣ កញ្ញា
- ពិធីបុណ្យ India Heritage – ៩ កញ្ញា



សាលាក្រុងឡូវែល

- ការប្រកួតLowell Kinetic Sculpture Race – ១៦ កញ្ញា
- ពិធីបុណ្យLowell Irish Festival* – ២៣ កញ្ញា
- ពិធីបើកការតាំងពិពណ៌ទីក្រុងមួយវប្បធម៌ច្រើន – ២៣ កញ្ញា
- ពិធីបុណ្យLatinx & Hispanic Festival – ៣០ កញ្ញា
- ពិធីបុណ្យLowell Celebrates Kerouac* – ៥-៩ តុលា
- ពិធីបុណ្យ El Encuentro: The Latin Film Experience* – ១៣-១៤ តុលា
- ពិធីបុណ្យខ្សែភាពយន្ត Lowell Asian American Film Festival* – ២០-២២ តុលា
- ពិធីបុណ្យ MonsterBash & Halloween Stroll – ២៨ តុលា
- ពិធីបុណ្យ City of Lights – ២៥ វិច្ឆិកា

ពេញមួយរដូវស្លឹកឈើជ្រុះ ទីក្រុងឡូវែលនឹងភ្លឺចែងចាំងជាមួយនឹងពិធីបុណ្យ និងព្រឹត្តិការណ៍នានាដែលផ្តល់អ្វីមួយសម្រាប់មនុស្សគ្រប់គ្នា។ សូមចូលរួមជាមួយយើង អបអរសាទរស្មារតីនៃឯកភាព ចម្រុះភាព និងសហគមន៍ដែលតាក់តែងទីក្រុងដ៏អស្ចារ្យរបស់យើង។

សម្រាប់បញ្ជីពេញលេញនៃអ្វីដែលកំពុងកើតឡើង និងនៅពេលណា

សូមចូលទៅកាន់៖ https://www.likelowell.com/







## Lowell Primary Care Center
## មណ្ឌលថែទាំសុខភាព Lowell

1075 Westford Street, Unit 204
Lowell, MA 01851 • (978) 455-7992

## Lynn Primary Care Center
## មណ្ឌលថែទាំសុខភាព Lynn

280 Union Street, Unit 402
Lynn, MA 01901 • (781) 780-7755



**Chhan Touch, FNP-BC**
ឆាន់ ទូច



**Practice Manager**
**Channa Khan, CMA**
អ្នកគ្រប់គ្រងគ្រូពេទ្យ
ចាន់ណា ខាន់



**Sophor Chhour, LMHC**
សុភ័រ ឈួ



**Nalyne Dom, FNP-BC**
ណាលីន ដំ



**Nida Lam, FNP-BC**
នីដា ឡាម



**Maredy Sar, DNP, NP-C**
ម៉ារីឌី ស



**Miadette Pheng-Phal, DNP, NP-C**
មីយ៉ាដេត ផេងផល

## Now Accepting New Patients
## ឥឡូវនេះ បើកទទួលអ្នកជំងឺថ្មី

***Family Medicine***
*ថែទាំសមាជិកគ្រួសារ*

***Behavioral Health***
*ថែទាំសុខភាពផ្លូវចិត្ត*

**We Accept MassHealth, Medicare and Other Health Insurances**
**Our Staff Speaks Khmer**

យើងទទួល **MassHealth** **Medicare** និងការធានារ៉ាប់រងសុខភាពផ្សេងៗ
បុគ្គលិករបស់យើងនិយាយភាសាខ្មែរ

# វិភាគភូមិសាស្ត្រពិភពលោកកំពុង ប្រែប្រួលខ្លាំងនៅទ្វីបអាហ្វ្រិក

**អឺរ៉ុប ថ្ងៃទី ៨ កញ្ញា ២០២៣**

នៅទ្វីបអាហ្វ្រិក: រដ្ឋប្រហារជាច្រើន បានផ្ទុះឡើងនៅតំបន់អាហ្វ្រិក នា ៤, ៥ ឆ្នាំចុងក្រោយនេះ ដោយសារប្រទេសនៅតំបន់នោះ ពីដើមជាតំបន់ក្រីក្រជាទីបំផុត តែឥឡូវមិនដូចពីមុនទៀតទេ គឺដោយសារធនធានក្រោមដី បានធ្វើឲ្យអណ្តូងរ៉ែជាច្រើន ផ្តល់ជាធនធានដល់ប្រទេសទាំងនោះ ឲ្យក្រោកឡើងជាប្រទេសអភិវឌ្ឍន៍សេដ្ឋកិច្ចព្រោងព្រាតបាន ដែលនេះ ដោយមិនផ្ទាប់ទៅនឹងការវិវឌ្ឍន៍ខាងវិជ្ជានឹងបញ្ញា បានបណ្តាលឲ្យមានការលូកដៃកេងចំណេញពីប្រទេសមហាអំណាចជាពិសេស ប្រទេសចិន នឹង រុស្ស៊ី ដែលរដ្ឋប្រហារយោធា ជាច្រើន បានផ្ទុះឡើង ដោយសារឥទ្ធិពលនៃមហាអំណាចជាពិសេសប្រទេសរុស្ស៊ី ដែលចង់ឲ្យឥទ្ធិពលរបស់ខ្លួន អាចគ្រប់គ្រងអំណាចក្នុងប្រទេសអាហ្វ្រិកមួយចំនួនបាន។

ចិន, រុស្ស៊ី នឹងឥណ្ឌា ចូលរួមដោយ



ពណ៌ក្រហមប្រទេសលោកខាងត្បូងទាំងមូល

ប្រទេសលោកខាងលិចយល់ឃើញថា ពីភូមិសាស្ត្រពិភពលោក បានប្តូររូបភាព ពីភូមិសាស្ត្រកំពូល២ដែលមានលោកខាងលិច នឹងលោកខាងកើត ឲ្យក្លាយទៅជាមានកំពូលទី ៣ ថ្មី ១ទៀតគឺ «លោកខាងត្បូងទាំងមូល» ដែលសំដៅទៅតំបន់អាហ្វ្រិកា នឹងអាមេរិកឡាទីន នឹង ឥណ្ឌា ដែលធ្លាប់ត្រូវគេជិះជាន់។ ហេតុអ្វី ? ពីព្រោះអត្រាចំនួនប្រជាពលរដ្ឋសរុប បានកើនឡើងលើសពីមហាប្រទេសទៅហើយហើយដោយសារមានប្រាក់ចំណូលប្រចាំឆ្នាំ ជាមធ្យមបានកើនខ្ពស់ គឺជា នេះជាអត្រាពលរដ្ឋដែលលើសចិននឹងឥណ្ឌារួមគ្នាទៅទៀត ។ រីឯអណ្តូងរ៉ែ ក៏បានផ្តល់ការងារ នឹង ប្រាក់ចំណូលខ្ពស់ ដែលធ្វើឲ្យជីវភាពពលរដ្ឋអាហ្វ្រិកាជាទូទៅ លែងរហេមរហាមទៀតហើយ។

ការប្តូរស្ថានភាពសេដ្ឋកិច្ចហ័សរបៀបអាហ្វ្រិកខាងត្បូង បានចងសម្ព័ន្ធសេដ្ឋកិច្ចជាមួយនឹងគ្នាជាប្រទេសមហាអំណាចថ្មីដែលហៅថា«ប្រ៊ីក» ដើម្បីសហការគ្នាទប់ទល់នឹងឥទ្ធិពលសេដ្ឋកិច្ចសហរដ្ឋអាមេរិក។ ចំណែកប្រទេសអាហ្វ្រិកមួយចំនួនទៀត ចងក្រងគ្នាជាសម្ព័ន្ធប្រទេសប្រជាធិបតេយ្យ គេហៅថា«អាសេដេអូ» នឹងនៅថ្មីៗនេះទៀត នៅតំបន់សាអែលមានរដ្ឋប្រហានៅប្រទេសអាហ្វ្រិកកណ្តាល ដឹកនាំដោយយោធា ជម្រុញដោយទាហ៊ានស៊ីឈ្នួលរុស្ស៊ី ដោយរុស្ស៊ីមានបំណងទាញយកផលចំណេញពីអណ្តូងរ៉ែទាំងឡាយនៅក្នុងតំបន់ ហើយបណ្តេញបារាំង ដែលជាដៃគូរសេដ្ឋកិច្ចប្រទេសអាហ្វ្រិក ឲ្យចាកចេញពីអាហ្វ្រិក ជាបន្ទាន់។ ស្ថានភាពនៅអាហ្វ្រិកបច្ចុប្បន្ន នៅច្របូកច្របល់ច្រើននៅឡើយ ពុំទាន់មានសហាថេរភាពទេ៕


WANT TO DRIVE FOR THE LRTA?

NOW HIRING

Full-Time Bus Drivers

CDL-A or CDL-B with Air Brake
and Passenger Endorsement required.
Other LRTA requirements may apply.




Monday - Saturday
5 Day Work Week
Some Split Shifts

*Full-Time Bus Drivers Receive:*
*Competitive Pay Rate*
*Medical & Life Insurance*
*401K • And More!*

Please send resume to General Manager at
customerservice@LRTA.com
Or Apply In Person

Lowell Regional Transit Authority
100 Hale Street • Lowell, MA • Mon-Fri: 8 am - 4 pm
978-452-6161 • www.LRTA.com

Lowell Regional Transit Authority
An Equal Opportunity Employer

THE LRTA IS NOW HIRING
A FULL-TIME MECHANIC



Must be 21 years old or older
with a clean driving record
Must have your own tools
Minimum of 2 years
technician experience
CDL-B license is a plus but not required
Other LRTA requirements may apply

*Competitive Pay Rate • Medical & Life Insurance*
*401K • And More!*

Please send resume to Director of Maintenance at
100 Hale Street, Lowell, MA 01851
or Email to customerservice@LRTA.com
For more information call: 978-452-6161 ext. 214

Lowell Regional Transit Authority
An Equal Opportunity Employer

# New Cambodian Prime Minister but Old Politic World News

From Page 02

risk when Hun Sen is out of power and old, who is scared? Foreigners, near or far, have never loved our Cambodians beyond the interests of their country! They are waiting for Cambodia to be like previous history again. Since the 15th century, foreigners invaded Cambodia for many times until the arrival of France. Only some land remains. France trained the king of Cambodia how to select officials who have the ability, knowledgeable to work in the palace, then some officials know how to come to work for the nation.

Last month, Cambodian protesters in Paris, France, expressed their displeasure with Cambodian politics, for not holding a fair national election and elect a current feudal leader. The Paris Peace Agreement in 1991 is still the basis for leading Cambodian politics peacefully.

# Coup in Gabon, Central Africa

On August 30, a coup took place in Bongo by a bodyguard general of the President of the Republic of the Congo, who took the President himself under house arrest and "annulled the newly announced election results." Fifteen minutes ago, President Bongo defeated his opponent by more than 60%. The coup was immediately seen as gaining popularity among the townspeople in Gabon, as well as many Gabonese refugees. There is no sign of Chinese or Russian intervention in Central Africa. France, a close development partner of President Bongo, also appears to have no accusations that France is colluding with the president.

The coup was seen as popular among the poor because President Ali Bhumibol Adulyadej succeeded his father, Omar Bongo, 14 years ago, who ruled for 41 years. It is alleged that the ambassador provided the information to Hussein, but he did not do so until the president was re-elected.

Gabon is one of the major developing countries in Africa, rich in mines that big countries need to have decent economic relations with foreign countries, raising the living standards of the people, which observers see as a place where superpowers compete and take advantage of each other. Since the colonization of Africa in 1955, France has not left the region but has remained an alliance of development partners.

On Monday, General Brice Nguema will be sworn in as caretaker president, and the party that lost last week will claim victory for the new rulers to find justice for themselves.

## Coup in Nigeria, North Africa, Sahel Region

In earlier July, in Nigeria, General Mohammed Bazum's bodyguards named Abdourahamane Tchiani staged a coup, imprisoned his president, and declared his own power in Nigeria on July 30, 2023. The coup stemmed from corruption, incompetence, and insecurity, but there were signs of encouragement from Russia and the Russian mercenaries "Wagner", who wanted the soldiers back to power for prosperity and the support of some neighboring countries like Mali, Burkina Faso, and Guinea, who want the same by the coup." The French embassy was besieged by protesters demanding the expulsion of France, but the 1,500-strong troops defending French embassy has not yet responded to the threats.

France, which has strengthened its embassy, despite declaring no support for the coup, said it was unbearable how long the United States and some European countries would be less interested in the coup. Keep France under control, but French President Francois Hollande still does not support the coup.




fate in the Sahel. But in neighboring areas such as the African Economic Community (AEC), there are also democratic countries do not support the coup, although in the city of General Tchiani, many people are protesting for the removal of the old president anyway.

France, the Nigeria's development partner, also did not support the coup, saying "the old president came to power with a legitimate election and bravely refused to resign as threatened

There are other countries in the Saale region that have been overthrown by successive military coups in the last three years, such as the Dominoes effect, including Mali, Guinea and Burkina Faso, which observers see as backed by the same Russian mercenaries and they ousted France, a former development partner. France is facing alone, no free country has helped, has already evacuated civilians, but has not yet withdrawn troops from those countries.

# War in Ukraine

We missed talking about the war in Ukraine for two months. We talk about it now because there are major new developments that should be reported: First, the famous Russian mercenary Brigadier General Prigozhin's plane was shot down by President Putin as punishment for daring to raise troops to threaten the Kremlin in three months ago. Russian lost its troops in large number and suffered heavy casualties in almost every battle, causing the Ukrainian army to invade Russian-held positions, despite slow progress in many places. Second, the United States and its NATO allies expressed some joy after seeing President Zelensky's forces capture the Orskov in the south and break through Russia's stronghold into Robotnik occupying the area. At that time, the Ukrainian flag was hoisted at two other places in the Russian-occupied areas. Ukraine continues to express dissatisfaction with its allies for not providing F16 fighter jets to its troops, that is why the counterattack has been slow.

Analysts have seen Russian forces, despite their strongholds defending their liberated areas, appear to have fallen heavily in the face of Ukrainian forces: more casualties, more surrendered, and more Russian rebel forces fought in many places in Russia. With increase of drones, Ukrainian dropped small bombs on cities in Russian territory, making the Russian people no longer see the war with Ukraine as small as before. The Ukrainian warships have started patrolling the Black Sea, where used to be controlled by Russian and Ukraine ships grain on two cargo ships without any threat from the Russian patrol vessel. The bridge connecting the Crimean Peninsula to Russian territory was regularly threatened by Ukrainian terrorism, and the Zelensky's army launched its first invasion of Crimea with the encouragement of the United States and Europe. With the help of the United States, the lack of fighter jets and the right to use the weapons of war from donor countries to attack Russian territory, Ukraine forces lost much to Russia, but Ukraine still pushed hundreds of kilometers into Russia, it has used its own drones to drop bombs, causing extensive damage around Moscow.

The loss of the Prigozhin mercenaries was replaced by another mercenary, the well-known Chechens, who vowed to remain loyal to President Putin. Tens of thousands of proxies are still present in many parts of Africa, leaving many observers convinced that the general is still alive.



# ជានា ខ្មែរ មករស់នៅ អាមេរិច

ដោយ: ឡុង មិត្តា

សមាគមន៍ខ្មែរប្រចាំរដ្ឋណតឃែរ៉ូឡាញណា ដែលហៅជាភាសារអង់គ្លេសថា Cambodia Association of NC ( CANC ) ដែលមាន លោក ថាច់ សីហា ជាប្រធាន កំពុងជួយរៀបចំ ដល់ ជនអន្តោប្រវេសន៏ខ្មែរមានកាន់ប័ណ្ណសំគាល់ របស់អង្គការសហាប្រជាជាតិ (UN) ដែលកំពុងរស់នៅប្រទេសថៃ មករស់នៅសហរដ្ឋអាមេរិច។

លោក ថាច់ សីហា បានមានប្រសាសន៏ ប្រាប់ថា ការរៀបចំបំពេញទម្រង់បែបបទ តាមផ្លូវច្បាប់ កំពុងប្រព្រឹត្ត និងដំណើរការ ទៅមុខ ។

"ក្រុមខ្ញុំកំពុងធ្វើរឿងហ្នឹង សំរាប់អោយ ជនអន្តោប្រវេសន៏ខ្មែរ 4នាក់ ដើម្បីមករស់នៅអាមេរិច។ ពួកគាត់ មានកាន់កាត UN" លោក ថាន់ សីហា បានមានប្រសាន៏ ថ្ងៃនេះ ពីរដ្ឋណសការ៉ូឡានណា។

លោក បានបន្ថែមទៀតថា យើងមិនអាច ជ្រើសរើស ជនអន្តោប្រវេសន៏ ដែលយើងស្គាល់ ហើយចង់បាននោះទេ តែក្រុមការងារគេ នឹងជ្រើសរើស ជនអន្តោប្រវេសន៏ និងជនភៀសខ្លួនខ្មែរ

**តទៅទំព័រទី១៣**



លោក ថាច់ សីហា ប្រធានសមាគមកម្ពុជា(North Carolina)

# Assuring Cambodians to live in America

**By: Long Mitta**

The Cambodian Association of North Carolina, known in English as the Cambodia Association of NC (CANC), chaired by Thach Seiha, is assisting Cambodian immigrants with United Nations (UN) residency in Thailand to come to live in the United States.

Mr. Thach Seiha said that the preparation of legal forms is underway and moving forward.

"My team is doing this for four Cambodian immigrants to live in the United States. They have UN cards," said Mr. Seiha from the state of Carolina.

He added that we could not recruit immigrants we knew and wanted, but the team would recruit Cambodian immigrants and refugees to live in the United States under the association's sponsorship.

"However, by the end of 2023, it will change, and the assurer may have the right to recruit refugees we know to live in the United States," he said.

Mr. Thach Seiha, President of the Cambodian Association of North Carolina (Cambodia Association of NC (CANC)) also intends to inform Cambodian-Americans who are eager to help secure Cambodian refugees in Thailand to live in the United States.

Recently, nine Cambodian refugees stranded in Thailand for more than 18 years have arrived in North Carolina, and Thach Seiha and his team are helping to build businesses based on their skills.

Mr. Thach Seiha
President of the Cambodian Association
North Carolina
(North Carolina)







តមកពីទំព័រទី ០៣

# ខ្មែរមាននាយករដ្ឋមន្ត្រីថ្មី...

គណបក្សភ្លើងទៀន បានត្រូវហាមឃាត់ ដោយចុះឈ្មោះចូលរួមបោះឆ្នោតមិនបាន ខាង«គណបក្សកែទម្រង់កម្ពុជា»មិន មានការទុកចិត្តលើភាពយុត្តិធម៌របស់ ការបោះឆ្នោតក៏ប្រកាសមិនចូលរួម រីឯ«គណបក្សរួបរួមជាតិ»បានបែកចេញ ពីគណបក្សរាជានិយម ក៏ពុំមានការ យោសនាអ្វីដែលនាំឲ្យប៉ះពាល់ដល់





លោកជំទាវ ឃួន សុដារី ជាស្ត្រីខ្មែរទី១ ដែលមានតំណែងជាប្រធានរដ្ឋសភាថ្មី

គណបក្សកាន់អំណាច ហើយក៏ មិន មានការគាំទ្រណាមួយពីគណបក្សប្រឆាំង អតីតសង្គ្រោះជាតិដែរ។ បន្ថែមពីករណី គម្រាមបក្សប្រឆាំង ក៏គ្មានអ្នកសង្កេតការ ដ៏គួរឲ្យទុកចិត្តប្រទេសណាចូលរួមទេ ដូច្នេះការរៀបចំបោះឆ្នោតប្រកបដោយ ភាពមន្ទិលសង្ស័យច្រើនយ៉ាងនេះ ប្រទេសលោកសេរីមិនអាចចាត់ទុកថា«ជា ការបោះឆ្នោតប្រជាធិបតេយ្យ»បានទេ។

នៅដំណាច់ខែសីហា២០២៣នេះ លោកកឹមសុខាជាអតីតប្រធានគណបក្ស សង្គ្រោះជាតិ ក៏រងការកាត់ទោស ពីសំណាក់តុលាការលោក ហ៊ុន សែន ឲ្យជាប់ទោស២៧ឆ្នាំពិបទក្បត់ជាតិ ដោយមិនអនុញ្ញាតិឲ្យជួបនរណា ផ្សេង ពីក្រុមគ្រួសារខ្លួនឯងនោះឡើយ។

ការប្តូរអំណាចប្រទេសរបៀបនោះ បានចោទជាសំនួរថា តើប្រទេសខ្មែរនឹង គេចរួចពីនឹមបរទេសកុម្មុយនីស្ត បាន ដែរឬទេ?

សំនួរនេះកើតឡើងពី តាំងពីកាល នៅក្នុងអំណាចលោកនាយករដ្ឋមន្ត្រី ចាស់ ហ៊ុន សែន ប្រទេសខ្មែរបាន ចាកចេញពីនយោបាយប្រទេសអព្យាក្រឹត ទៅកាន់របបរណបប្រទេសចិន ផ្តាច់ការ និយម សភាឯកបក្ស ដូចគ្នានឹងប្រទេស ចិនកុម្មុយនិស្តប៉េកាំងដែរ ហើយទទួល រង្វាន់ពីចិនយ៉ាងស្តុកស្តមផង, ដូច្នេះគេ អាចសន្និដ្ឋានបានយ៉ាងងាយស្រួលថា ដង្ហាបឥទ្ធិពលលោក ហ៊ុន សែន នឹង ប្រទាញការគ្រប់គ្រងអ្នកជំនាន់ក្រោយ ឲ្យធ្លាក់ទៅក្នុងកណ្តាប់ដៃរបបកុម្មុយនិស្ត ដដែលដូចមុន។ លោក ហ៊ុន ម៉ាណែត ជាកូន នឹងជានាយករដ្ឋមន្ត្រីខ្មែរថ្មីក៏បាន ថ្លែងសម្តែងការដឹងគុណចំពោះឪពុក ខ្លួនចំពោះការបន្តរដំណែងថ្មីនេះរួចហើយ ដែរ។

បន្ថែមពីដំណែងបន្តពូជ ស្រដៀងគ្នា នឹងរបបរាជានិយមដែរនោះ លោក ហ៊ុន ម៉ាណែត បានឡើងជារដ្ឋបុរសម្នាក់ ដោយមិនដែលធ្លាប់មានបទពិសោធន៍ ជាអ្នកនយោបាយក្នុងប្រទេសឬក៏កិច្ចការ បរទេសម្តងណាទេ ហើយដំណែងយោ ធាជាឧត្តមសេនីយទៀតសោត ក៏បាន ពីគ្រួសារនិយមដូចគ្នាដែរ ដូច្នេះលោក ហ៊ុន សែន អាចនឹងគិតថា«គ្មានបទពិ សោធន៍ ក៏អាចមានសមត្ថភាពគ្រប់គ្រង ប្រទេសបានដែរ ឲ្យតែមានសញ្ញាប័ត្រ ធំទៅ វាគ្រប់គ្រាន់ហើយ» ហើយបើ មានការផ្លោះផ្លោយអ្វីកាលណា លោក ហ៊ុន សែន នឹងត្រឡប់មកយកដំណែង ដើមរបស់លោកវិញ ក៏បានដែរ ដោយ ឥឡូវនេះ លោកត្រូវទៅយកដំណែង ប្រមុខរដ្ឋស្តីទី ឲ្យបានហើយ មិនខ្វល់ថា ព្រះមហាក្សត្រ យល់ព្រមឬក៏អត់នោ ទេ។ ការប្រថុយប្រថាន នៅពេលដែល លោក ហ៊ុន សែន អស់មានអំណាច ហើយអាយុជរាទៅហើយនោះ តើធ្វើឲ្យ នរណាខ្លាចខ្លះទៅ? បរទេស ទាំងជិត ឬឆ្ងាយ គេមិនដែលស្រឡាញ់ខ្មែរយើង ឲ្យហួសពីផលប្រយោជន៍របស់ប្រទេស គេនោះទេ! គេរង់ចាំតែប្រវត្តិនៃកម្ពុជា មានដំណើរដូចសតវត្សមុននោះម្តង ទៀត, គឺតាំងពីសតវត្សទី១៥មកហើយ បរទេសវាយលុក យកប្រទេសខ្មែរដែល ធ្លាប់ជាមហានគរ បានច្រើនដងរហូតដល់ បារាំងមកដល់ ទើបបាននៅសល់ដីខ្លះ បារាំងបានបង្ហាត់ស្តេចស្រុកខ្មែរ ឲ្យចេះ ជ្រើសយកមន្ត្រី ដែលមានសមត្ថភាព មានចំណេះច្រើន ឲ្យមកធ្វើការក្នុងវាំង ក្រៅពីក្រុមគ្រួសារខ្លួនឯង ទើបបាន អ្នកចេះ ប្តើមចូលមកធ្វើការជូនជាតិ ប្រទេសជាតិបានហ្វឹងហ្វឺនបន្តិច។

បាតុករខ្មែរនៅក្រុងប៉ារីសប្រទេស បារាំង បានសម្តែងមតិ កាលពីខែមុន នេះ មិនយល់ស្របតាមនយោបាយនៅ កម្ពុជា ដែលមិនបានបោះឆ្នោតជាតិឲ្យ មានភាពយុត្តិធម៌ ហើយ ជ្រើសរើស ថ្នាក់ដឹកនាំប្រទេស តាមបែបសក្តិភូមិ នាបច្ចុប្បន្ននោះឡើយ ពួកគេយល់ថា កិច្ចព្រមព្រាងក្រុងប៉ារីស ឆ្នាំ១៩៩១ នៅតែជាមូលដ្ឋានសម្រាប់ដឹកនាំនយោបាយ កម្ពុជា ឲ្យបានជានាគ្នាយ៉ាងសុខសន្តិភាព បាននៅឡើយ៕



# លោក វីរៈ អ៊ុយ ប្រកាសបេក្ខភាព ក្រុមប្រឹក្សាក្រុងឡូវែល

ទីក្រុងឡូវែល ថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០២៣ - លោក វីរៈ អ៊ុយ ដែលជាអ្នកអប់រំដ៏ឧស្សាហ៍ព្យាយាម និងជាសកម្មជនសហគមន៍ មានមោទនភាពក្នុងការប្រកាសបេក្ខភាពរបស់លោកសម្រាប់ក្រុមប្រឹក្សាក្រុងឡូវែល។ ជាមួយនឹងការ



ប្តេជ្ញាចិត្តយ៉ាងជ្រាលជ្រៅចំពោះការអប់រំ ចម្រុះភាព និងសមធម៌ លោក វីរៈ មានបំណងបម្រើប្រជាជននៅទីក្រុងឡូវែលដោយទឹកចិត្ត និងការលះបង់ ដោយខិតខំបង្កើតអនាគតដ៏ត្រចះត្រចង់សម្រាប់អ្នករស់នៅក្នុងទីក្រុងឡូវែលទាំងអស់។

លោក វីរៈ ជឿជាក់ថា នៅពេលដែលយើងងើបចេញពីជំងឺរាតត្បាត ទីក្រុងឡូវែលប្រឈមមុខនឹងបញ្ហាជាច្រើន ក៏ដូចជាឱកាសដ៏អស្ចារ្យផងដែរ។ ទាំងសកម្មភាពធំ និងតូចគឺមានសារៈសំខាន់។ គ្រប់ពន្លឺភ្លើងតាមដងផ្លូវ គ្រប់គ្រលុកទឹក សួនឧទ្យាន គ្រប់ថ្នាក់រៀន និងគ្រប់អាជីវកម្មទាំងអស់ បានដាក់មូលដ្ឋានគ្រឹះសម្រាប់គុណភាពជីវិតកាន់តែប្រសើរឡើងសម្រាប់ប្រជាជនក្រុងឡូវែល ទាំងអស់គ្នា។

ក្នុងនាមជាអ្នកអប់រំដែលមានបទពិសោធន៍ លោកបានមើលឃើញពីអំណាចផ្លាស់ប្តូរនៃការអប់រំ និងសារៈសំខាន់នៃចម្រុះភាព និងសមធម៌។ លោក អ៊ុយ វីរៈ ជឿជាក់ថារួមគ្នាយើងអាចបង្កើតទីក្រុងឡូវែលឱ្យកាន់តែរឹងមាំ និងចូលរួមគ្នាបន្ថែមទៀត។ លោកឧទ្ទិសដល់ការកែលម្អការអប់រំ ការកែលម្អសុវត្ថិភាពសាធារណៈ ការពង្រីកកម្មវិធីសង្គមដែលមានឥទ្ធិពល និងជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏រឹងមាំនៅក្នុងទីក្រុងឡូវែល។

លោក វីរៈ ចង់កសាងសហគមន៍ដែលផ្តល់ឱកាសដល់ប្រជាជនទាំងអស់ឱ្យមានភាពរីកចម្រើន។

បច្ចុប្បន្ន លោក វីរៈ មានតួនាទីជានាយកកម្មវិធីគាំទ្រសិស្សនៅសកលវិទ្យាល័យ Middlesex Community College។ លោកបានបម្រើការនៅក្នុងក្រុមប្រឹក្សានៃអង្គការមិនស្វែងរកប្រាក់កម្រៃជាច្រើន រួមទាំងកាកបាទក្រហមអាមេរិក និងបានកាន់តំណែងជាប្រធានក្រុម ប្រឹក្សាភិបាលសម្រាប់សមាគមជួយគ្នាទៅវិញទៅមកនៃទីក្រុងឡូវែល ហៅកាត់ថា (CMAA)៕

# Virak Uy Announces Candidacy for Lowell City Council At-Large

Lowell, September 1, 2023 - Virak Uy, a dedicated educator and community activist, is proud to announce his candidacy for Lowell City Council At-Large. With a profound commitment to education, diversity and equity, Virak aims to serve the residents of Lowell with passion and dedication, striving to create a brighter future for all Lowell residents.

Virak believes that as we emerge from the pandemic, Lowell faces many challenges as well as great opportunities. Both big and small actions matter. Every street light, every pothole, every park, every classroom and every business, lays the foundation for a better quality of life for all Lowellians.

As an experienced educator, he has witnessed the transformative power of education and the importance of diversity and equity. Mr. Uy believes that together, we can create a stronger and more inclusive Lowell. He is dedicated to improving education, improving public safety, expanding impactful social programs, and fostering strong economic development in the city of Lowell. Virak wants to build a community that provides opportunities for all residents to thrive.

Virak Currently serves as the holistic student support program director at Middlesex Community College. He has served on the boards of various nonprofit organizations, including the American Red Cross, and held the position of Board Chair for the Cambodian Mutual Assistance Association of Lowell (CMAA).

តមកពីទំព័រទី ១១

## ធានាខ្មែរមករស់នៅអាមេរិក

អោយមករស់នៅអាមេរិច ក្រោមការធានា (ស្ប៉ានស័រ) របស់ សមាគមន៏។

លោក បានបញ្ជាក់ ថា តែយ៉ាងណា នៅចុងឆ្នាំ2023 គេនឹងកែប្រែ ហើយ អ្នកធានា អាចមានសិទ្ធិជ្រើសរើស ជនភៀសខ្លួន ដែលយើងស្គាល់ អោយមករស់នៅសហរដ្ឋអាមេរិចបាន ។

លោក ថាច់ សីហា ប្រធានសមាគមន៏ខ្មែរប្រចាំរដ្ឋណតយែរ៉ូឡាញណា Cambodia Association of NC ( CANC ) ក៏មានបំណង ផ្តល់ដំណឹង ដល់ខ្មែរ អាមេរិចកាំង ដែលមាន ទឹកចិត្ត ចង់ជួយ ធានា ដល់ខ្មែរភៀសខ្លួន ដែលកំពុងនៅ ប្រទេសថៃ អោយមករស់នៅសហរដ្ឋអាមេរិច។

ថ្មីៗនេះ មាន ជនភៀសខ្លួនខ្មែរ ចំនួន 9នាក់ ដែលជាប់នៅប្រទេសថៃជាង 18ឆ្នាំ បានមកដល់ រដ្ឋណសការ៉ូឡាញណា ហើយ លោក ថាច់ សីហា និងក្រុមការងារ កំពុងជួយបន្ថែម ក្នុងការទំនាក់ទំនងបង្កើត អាជីវកម្ម ទៅតាមជំនាញ របស់ពួកគេ។

លោក ថាច់ សីហា
ប្រធានសមាគមន៏កម្ពុជាប្រចាំ
រដ្ឋណតយែរ៉ូឡាញណា
(North Carolina)



# ក្រោយបោះបង្គោលព្រំដែនជាមួយវៀតណាមពលរដ្ឋត្បូងឃ្មុំទាមទារឲ្យយកដីស្រែនិងភូមិពីវៀតណាមមកវិញ

ពលរដ្ឋជាច្រើនគ្រួសាររស់នៅក្នុងស្រុកមេមត់ខេត្តត្បូងឃ្មុំនៅតែអាស្រ័យផល និងដាំដុះលើដីធ្វើចម្ការ កេរឪពុកម្ដាយរបស់ពួកគាត់ដែលបាត់បង់ទៅវៀតណាម ក្រោយពីបោះបង្គោលព្រំដែន។

ពួកគាត់អះអាងថា អាជ្ញាធរខ្មែរ និងវៀតណាម បានពន្លឿនបោះបង្គោលព្រំដែននៅតំបន់នោះ ដោយលាក់លៀមក្នុងពេលកម្ពុជាកំពុងរាលដាលជំងឺកូវីដ-១៩ និងមានវិបត្តិនយោបាយ។

នៅរយៈពេលជាង ៣ឆ្នាំចុងកន្លងទៅនេះ ចាប់តាំងពីឆ្នាំ២០២០ ក្នុងពេលដែលពលរដ្ឋកម្ពុជាកំពុងខ្វល់ខ្វាយការរីករាលដាលជំងឺកូវីដ១៩ បែរជារដ្ឋាភិបាលកម្ពុជា-វៀតណាមពន្លឿនបោះបង្គោលព្រំដែនដោយស្ងាត់ៗ និងលាក់បាំង ឋិតក្នុងខេត្តត្បូងឃ្មុំ។

ពលរដ្ឋអះអាងថា តំបន់ដែលអាជ្ញាធរកម្ពុជា និងវៀតណាម បោះបង្គោលព្រំដែន គឺឋិតក្នុងឃុំទន្លូង ឃុំជាំក្រវៀន ឃុំជាំ ឃុំចាន់មូល និងឃុំដារ ស្រុកមេមត់ ក្នុងចន្លោះបង្គោលព្រំដែនលេខ ៩៥ រហូតដល់បង្គោលលេខ ៩៨។

ពលរដ្ឋភាគច្រើនមិនបានដឹងរឿងរ៉ាវនេះទេ ហើយនៅគ្រាដែលពួកគាត់ប្រទះឃើញ បង្គោលព្រំដែន បោះចំកណ្ដាលដីស្រែកេរដូនតារបស់ពួកគាត់ទើបផ្អើលឆោឡោ អ្នកខ្លះស្រែកយំ និងខ្លះទៀតនៅស្ងៀមបៀមទុក្ខកង្វល់មិនហ៊ានតវ៉ា ខ្លាចអាជ្ញាធរធ្វើបាប និងប្ដឹងទៅតុលាការ។

អ្នកភូមិថា ក្នុងចន្លោះបង្គោលព្រំដែនលេខ៩៥ ឋិតក្នុងភូមិជើង ឃុំជាំ ស្រុកមេមត់ ក្រោយពីបោះបង្គោលព្រំដែនរួចរាល់ អាជ្ញាធរវៀតណាម បានពន្លឿនសាងសង់ផ្លូវក្រវាត់ព្រំដែនគ្រប់កន្លែង ធ្វើឱ្យដីស្រែចម្ការរបស់ពលរដ្ឋខ្មែររាប់រយហិកតារ បានបាត់បង់ទៅវៀតណាមកាន់កាប់។

ពលរដ្ឋរស់នៅស្រុកមេមត់ ថ្លែងសុំមិនបញ្ចេញឈ្មោះ ប្រាប់វិទ្យុអាស៊ីសេរីថា ពេលនេះមានពលរដ្ឋជាច្រើនគ្រួសាររស់នៅភូមិនេះនៅតែក្លាហាន ទៅប្រមូលផលចម្ការដោយបេះផ្លែដូង ស្វាយ និងទុរេន លើដីរបស់ខ្លួន ដែលវៀតណាមកំពុងកាន់កាប់នាពេលបច្ចុប្បន្ន។

លោកបញ្ជាក់ថា ពលរដ្ឋទាំងនោះមិនសុខចិត្តចំពោះការបោះបង្គោលព្រំដែនមិនត្រឹមត្រូវ និងលាក់បាំងបែបនេះឡើយ។

ពលរដ្ឋសុំលាក់ឈ្មោះ៖ «ក្រោយពីធ្វើផ្លូវក្រវាត់ចម្ការស្វាយមួយចំនួន នៅ






ខាងត្បូងផ្លូវ មានន័យថា នៅខាងវៀតណាម។ តែពលរដ្ឋខ្មែរយើង ខ្ញុំសរសេរនៅភូមិជើង ទុរេនគាត់នៅតែដុះ ហើយដូនតាគាត់នៅជ្រោង។ ខ្ញុំជឿថា នៅថ្ងៃខាងមុខ នឹងមានបញ្ហាទៀតដីអស់ហ្នឹង»។

អ្នកស្រុកអះអាងថា ភូមិអំផុល និងក្រអូប (អ្នកស្រុកហៅក្រៅថា ភូមិភោគ) ក្នុងឃុំចាន់មូលដែលមានពលរដ្ឋខ្មែររាប់ពាន់គ្រួសាររស់នៅតាំងពីបុរាណកាលមក បានបាត់បង់ទៅវៀតណាមកាន់កាប់ទាំងស្រុងហើយ។

ភូមិទាំងនេះ មានផ្ទះខ្មែរបុរាណ និង

តទៅទំព័រទី១៦

# After Border Post Tbong Khmum Residents Appeal to New Government to Resolve Loss Farmlands and Villages to Vietnam Post

Residents of Tbong Khmum province are calling on the new government to resolve the issue of farmlands and some villages lost to Vietnam after the border post was demarcated recently.

The villagers used to protest and get angry with the officers of expertise who set up border posts in the middle of their parents' farmlands.

Hundreds of families in Chanmoul, Rong and Choam commune, in Memot district, Tbong Khmum province, are still heartbroken as they recall border-related issues where villagers suffer many injustices in losing their farmlands, birth places and intimidation in court when they protested the demarcation of the border with Vietnam in the past.

These residents have always been quiet and patient, not daring to speak out and protest over this issue for fear of being imprisoned and persecuted by the authorities.

Residents of Chan Moul commune, Memot district, Tbong Khmum province, told RFA on condition of anonymity that authorities were delaying the settlement of land disputes along the border by villagers complaining about losing their parent farmlands after the border post was demarcated.

She said the areas that lost farmlands to Vietnam along the border were in Rong, Choam, Chan Moul, Treak and Choam Kravien communes.

Residents hide their names: “we sorry for the loss of lands but do not know what to do? Every word we heard we would be imprisoned if we dared to speak up. I would like to request him (Mr. Hun Manet) to look after our country border for the sake of our children.”

Villagers claim that people living in the border area lack warmth, not only they lost their ancestral farmlands, but have become victims in court, and so far at least six people have been sued in court for protesting for their lost farmlands to Vietnam.

Most of the people abandoned the land that Vietnam encroached on because they did not want to have problem and did not want to spend time suing.

Chan Moul villagers' farmland along the border with a total of 300 hectares, which Vietnam has controlled since 1998, the government has agreed to set up a border post with the Vietnamese side, and the Vietnamese side has handed over part of the land area of 70 hectares to the Khmer authorities.

Residents claim that Chan Sala village is located at Veal Tbong, an ancient village where Cambodians have lived for generations and now has become a Vietnamese-controlled deserted land.

In Tanong village in Chan Moul commune, between border posts 97 to 99, many hectares of farmland were controlled by Vietnam, with some border posts in the center of the villagers' farmland.

In addition, Ampul and Phok villages, the oldest villages in Chan Moul commune in present-day, were also occupied by Vietnam after the government set up a border post with Vietnam from 2010 to 2022. The Ministry of Interior has removed the names of these villages

Please see /16

# មហាវិទ្យាល័យសហគមន៍ក្នុងតំបន់ផ្តល់ជូន ការត្រៀមប្រឡងសមមូលវិទ្យាល័យដោយឥតគិតថ្លៃ

ដោយៈកាសែតខ្មែរប៉ុស្ដិ៍សហរដ្ឋអាមេរិក

មជ្ឈមណ្ឌលសិក្សាសម្រាប់មនុស្សពេញវ័យនៃមហាវិទ្យាល័យ Middlesex Community College (ALC) ផ្តល់ជូនដោយមិនគិតថ្លៃនូវវគ្គសិក្សាអប់រំជាមូលដ្ឋានសម្រាប់អ្នកសិក្សាពេញ វ័យរបស់រដ្ឋម៉ាសាឈូសេត ដែលមានអាយុចាប់ពី ១៦ ឆ្នាំឡើងទៅ។ នេះរួមបញ្ចូលទាំងវគ្គត្រៀមសម្រាប់ការប្រឡងកៅអី GED® និង HiSET® ដែលអ្នករស់នៅរដ្ឋម៉ាសាឈូសេត ឥឡូវនេះអាចទទួលបានដោយមិនគិតថ្លៃសម្រាប់ពួកគេ។



បុគ្គលិកមជ្ឈមណ្ឌលសិក្សាមនុស្សពេញវ័យ MCC Joy DeHaan, Amy O'Hallaron, Karen Spengler និង Heather Williams

Katherine Innis នាយកកម្មវិធីរបស់ MCC នៃ ALC បាននិយាយថា "នាយកដ្ឋានបឋមសិក្សា និងមធ្យមសិក្សាបានប្រកាសថា ពេលនេះរដ្ឋកំពុងរ៉ាប់រងថ្លៃធ្វើតេស្ត GED® និង HiSET® ដំបូងរបស់អ្នករស់នៅរដ្ឋម៉ាសាឈូសេត តាមមុខវិជ្ជានីមួយៗ បូករួមទាំងការប្រឡងឡើងវិញចំនួនពីរ" ។ "ជាមួយនឹងការធ្វើតេស្តដោយឥតគិតថ្លៃ និងវគ្គត្រៀមរៀបចំដោយឥតគិតថ្លៃ ដូចជាកម្មវិធីដែលផ្តល់ជូននៅមជ្ឈមណ្ឌលសិក្សាសម្រាប់មនុស្សពេញវ័យ MCC ការទទួលបានលិខិតសម្គាល់វិទ្យាល័យបានក្លាយជាសមធម៌សម្រាប់មនុស្សពេញវ័យទាំងអស់នៅក្នុងរដ្ឋ" ។

ALC របស់ MCC ត្រូវបានបង្កើតឡើងដើម្បីជួយអ្នកសិក្សាពេញវ័យឱ្យទទួលបាននូវភាពល្អប្រសើរឡើងផ្នែកអក្ខរកម្ម គណិតវិទ្យា និងជំនាញកុំព្យូទ័ររបស់ពួកគេ ដើម្បីទទួលបានសមមូលវិទ្យាល័យ។ តាមរយៈកម្មវិធីរបស់ MCC និងការបញ្ចប់ការប្រឡងដោយជោគជ័យ សិស្សានុសិស្សត្រូវបានដាក់ឱ្យស្ថិតក្នុងទីតាំងកាន់តែល្អប្រសើរ ដើម្បីបន្តការសិក្សារបស់ពួកគេ និងឈានទៅមុខក្នុងអាជីពរបស់ពួកគេ។

ចាប់ពីខែកញ្ញាតទៅ MCC នឹងផ្តល់ថ្នាក់រៀនពេលថ្ងៃ និងពេលល្ងាចសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទាំងពីរ។ ថ្នាក់រៀនពេលថ្ងៃនឹងធ្វើឡើងចាប់ពីម៉ោង ៩ ព្រឹកដល់ម៉ោង ១២:៣០ យប់ រៀនដោយផ្ទាល់នៅថ្ងៃអង្គារ និងអនឡាញនៅថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍។ ថ្នាក់រៀនពេលល្ងាចមានអ៊ីនធឺណិតត្រឹមម៉ោង ៦ ល្ងាច ដល់ម៉ោង ៩ យប់ នៅថ្ងៃច័ន្ទ និងថ្ងៃ ពុធ។ វគ្គតាមអនឡាញគឺមានការបង្រៀនផ្ទាល់ និងតាមរយៈ Zoom។

ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចូលរៀនថ្នាក់ដោយឥតគិតថ្លៃ សិស្សត្រូវតែជាអ្នករស់នៅក្នុងរដ្ឋម៉ាសាឈូសេត។ ដើម្បីបញ្ចប់ការសិក្សា សិស្សក៏ត្រូវមានកុំព្យូទ័រដែលមានក្តារចុច មានអូប៉ាល័រ មីក្រូហ្វូន និងកាមេរ៉ា មានអ៊ីនធឺណិតខ្លាំង អាចចូលរួមក្នុងវគ្គបន្តផ្ទាល់ ទាំងការសិក្សាក្នុងថ្នាក់ផ្ទាល់ និងតាមអ៊ីនធឺណិត ព្រមទាំងបំពេញកិច្ចការផ្ទះនៅខាងក្រៅថ្នាក់ផងដែរ។

ការចុះឈ្មោះឥឡូវនេះត្រូវបានបើកសម្រាប់វគ្គរដូវស្លឹកឈើជ្រុះ។ សម្រាប់ព័ត៌មានបន្ថែម សូមអ៊ីម៉ែល alc@middlesex.mass.edu ឬទូរស័ព្ទទៅលេខ 781-280-3665៕

# Local Community College Offers FREE High School Equivalency Exam Prep

**By Khmer Post USA**

Middlesex Community College's Adult Learning Center (ALC) offers free noncredit, basic education courses for Massachusetts adult learners who are 16 years or older. This includes preparation courses to sit for the GED® and HiSET® exams, which Mass. residents can now take at no cost to them.



MCC Adult Learning Center staff Joy DeHaan, Amy O'Hallaron, Karen Spengler & Heather Williams

"The Department of Elementary and Secondary Education has announced that the state is now covering the cost of Massachusetts residents' initial GED® and HiSET® tests in each subject, plus two retakes," said Katherine Innis, MCC's Program Director of the ALC. "With free testing and free preparation courses such as those offered at the MCC Adult Learning Center, obtaining a high school credential has become far more equitable for all adults in the state."

MCC's ALC is designed to help adult learners improve their literacy, mathematics and computing schools in order to earn a high school equivalency. Through MCC's program and successful completion of the exams, students are placed in a better position to continue their education and advance in their careers.

Starting in September, MCC will offer day and evening classes for both high school equivalency exams. Daytime classes will be held from 9 a.m. to 12:30 p.m. in-person on Tuesdays and online on Wednesdays and Thursdays. Evening classes are online only from 6 p.m. to 9 p.m. on Mondays and Wednesdays. Online sessions are live and interactive taught over Zoom.

To qualify to take the free classes, students must be a resident of Massachusetts. In order to complete classes, students must also have a computer with a keyboard, speaker, microphone and camera, reliable internet access, be able to attend and participate in live class sessions in-person and online, as well as complete homework outside of class.

Registration is now open for the Fall session. For more information, email alc@middlesex.mass.edu or call 781-280-3665.

តមកពីទំព័រទី ១៤

# ក្រោយបោះបង្គោលជាមួយវៀតណាម

លំនៅឋានចាស់ៗរបស់ដូនតាខ្មែររាប់រយខ្នង ហើយអាជ្ញាធរវៀតណាម បានបិទសិទ្ធិពួកគាត់ មិនឱ្យរៀនអក្សរខ្មែរ បន្ទាប់ពីរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាប្រើប្រាស់ សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥។

ពលរដ្ឋខ្មែររស់នៅក្នុងភូមិទាំងនេះ នៅតែលួចបញ្ជូនកូនឱ្យមករៀនភាសាខ្មែរ ក្នុងទឹកដីខ្មែរ នៅកៀកតំបន់ព្រំដែន ខេត្តត្បូងឃ្មុំ។

ភូមិទាំងនេះ បើទោះបីជាវៀតណាមកាន់កាប់ក្ដី ក៏ពួកគាត់អាចឆ្លងដែនមកដីខ្មែរបានធម្មតា ក៏ប៉ុន្តែក្រោយពីបោះបង្គោលព្រំដែនរួចរាល់ និងសង់ផ្លូវក្រវាត់ព្រំដែន អាជ្ញាធរវៀតណាមមិនអនុញ្ញាតឱ្យពួកគាត់ចេញចូលមកខ្មែរដោយសេរីឡើយ។

អ្នកភូមិបន្ថែមទៀតថា ក្រោយពីអាជ្ញាធរកម្ពុជា និងវៀតណាម បោះបង្គោលព្រំដែនរួចរាល់ ក្នុងស្រុកមេមត់ និងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ពួកគាត់តែងតែលើកគ្នាតវ៉ា និងប្ដឹងទៅអាជ្ញាធរឱ្យជួយដោះស្រាយដីស្រែចម្ការរបស់ពួកគាត់តែគ្មានបានផលឡើយ។

ដែនដីភូមិអំផុល លាតសន្ធឹងទល់នឹងវត្តស្រែតានង ហើយអាជ្ញាធរខ្មែរ និងវៀតណាម បានឯកភាពគ្នាបោះបង្គោលព្រំដែន និងសង់ផ្លូវក្រវាត់ព្រំដែន នៅជាប់នឹងរបងវត្តនេះ។

លើសពីនេះទៀត បន្ទាប់ពីបោះបង្គោលព្រំដែនរួច អាជ្ញាធរវៀតណាម បានក្ដាប់យ៉ាងណែន និងសាងសង់ផ្លូវក្រវាត់ព្រំដែនគ្រប់ច្រកល្ហក សូម្បីតែប៉ុស្តិ៍ព្រំដែនខ្មែរមួយចំនួនក៏ត្រូវបានវៀតណាមកាន់កាប់ដែរ។

ពលរដ្ឋថ្លែងសុំលាក់ឈ្មោះ៖ «បោះបង្គោលព្រំដែនពិបាកណាស់ស្រេចតែគេចង្អុល ស្រេចតែគេបង្ហាញ។ ពលរដ្ឋភាគច្រើនគឺមិនបានដឹងបានឮទេ គេឃុបឃិតគ្នាគេទៅ និយាយគ្នាគេទៅ។ ពលរដ្ឋមិនដឹងទេ ទាល់តែថា ស្អែកឡើងទាន់តែឃើញបង្គោលចំ នាំគ្នាស្រែកយំ អ្នកខ្លះសំងំ និងអ្នកខ្លះមិនហ៊ាននិយាយបៀមទុក្ខ»។

ពលរដ្ឋម្នាក់ទៀតរស់នៅភូមិចាន់មូល លោក ឈីន ឆន មានប្រសាសន៍ថា គ្រួសារលោកមានដីស្រែសរុបជាង ៧ ហិកតារ ក៏ប៉ុន្តែនៅពេលដែលអាជ្ញាធរបោះបង្គោលព្រំដែន និងធ្វើផ្លូវក្រវាត់ព្រំដែនរួចនៅសល់តែ ១ហិកតាប៉ុណ្ណោះ ហើយ ៦ហិកតារទៀតរបូតទៅវៀតណាមគ្រប់គ្រង៖

លោក ឈីន ឆន៖ «ខ្ញុំឈឺចាប់ពេកហើយ នៅតែសោកស្ដាយដែរ ធ្វើម៉េចវាជាការជាក់ស្ដែង បើសិនអនាគតទៅក្មេងជំនាន់ក្រោយ អាចដោះស្រាយបានពីមួយជំនាន់ ទៅមួយជំនាន់ តាមច្បាប់អន្តរជាតិ ខ្ញុំក៏ត្រេកអរដែរ»។

ចំណែកភូមិត្រពាំងផ្លុង ស្រុកពញាក្រែកមានពលរដ្ឋចំនួន ១០៦គ្រួសារ មានទំនាស់ដីធ្លីជាច្រើនឆ្នាំហើយ គឺក្រោយពេលដែលរដ្ឋាភិបាលកម្ពុជា និងវៀតណាមបានបោះបង្គោលព្រំដែនលេខ១១៤ ដល់លេខ១១៩ រួចរាល់ ធ្វើឱ្យពួកគាត់បាត់បង់ដីស្រែកេរដូនតាទំហំជាង ៦០ហិកតារ។

ទិដ្ឋភាពបង្គោលព្រំដែនលេខ៧ ស្ថិតនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅថ្ងៃទី២ កញ្ញា ២០២៣។ រូបៈ ពលរដ្ឋផ្ដល់ឱ្យ

អ្នកភូមិអះអាងថា ទាហានវៀតណាមតែងតែកាន់កាំភ្លើង ដំបងឆក់ និងខ្នោះដៃ ឆ្លងដែនចូលមកបណ្ដេញ និងរើខ្ទមចាំចម្ការរបស់ពួកគាត់ចោលដោយអះអាងថា ជាដីតំបន់ព្រំដែន។

យុវជនដែលតែងចុះពិនិត្យតំបន់ព្រំដែន លោក សឿន មករា ស្នើឱ្យរដ្ឋាភិបាលថ្មី ពន្លឿនដោះស្រាយបញ្ហានេះជូនពលរដ្ឋ ដោយយុត្តិធម៌និងអនុញ្ញាតឱ្យយុវជនចូលរួមតាមដានរឿងនេះឱ្យបានទូលំទូលាយ។

លោក សឿន មករា៖ «រដ្ឋាភិបាលថ្មីចាំបាច់ត្រូវមានយន្តការយ៉ាងម៉េច លុបបំបាត់ភាពមន្ទិល និងបង្ហាញពលរដ្ឋខ្លួនឯង មានទំនុកចិត្តលើខ្លួន។ ត្រូវមានយន្តការច្បាស់លាស់ជំរុញពលរដ្ឋខ្លួនឯងឈ្មុសឈ្មុលរឿងឯកសារបូរណភាពទឹកដីរបស់ខ្លួន»។

វិទ្យុអាស៊ីសេរី មិនទាន់អាចទាក់ទង

តទៅទំព័រទី២៣

# Tbong Khmum Residents Appeal to New Government to Resolve Loss Farmlands and Villages to Vietnam After Border Post

From Page 14

from the commune / Sangkat administration management list.

In the past, villagers often gathered to gossip about the officials from the Joint Border Affairs Committee, who went to explain them to accept the demarcation, which they allegedly caused the loss of hundreds of Cambodian farmlands.

A resident named Chhay Vit publicly reprimanded former Senior Minister of the Joint Border Affairs Committee, Mr. Var Kimhong, that Ampul and Phok villages were not lost during the Khmer ancestral period but disappeared during this period.

Chhay Vith says: "The border committee came, they stood and watched,




they said, um, now they say, Cambodia, the border, there are both national and international law, how long has the map been made? They tell? It is said that we have been clearing since our ancestors watched the land, we do not know what theirs and ours is, now we have a map. They came to quell our anger. This land we have been making since our ancestors, we do not know how many maps. Ampul and Thlok villages are all Khmer villages, not lost since our ancestors, lost in my time. He said that Khmer villages encroach Vietnamese territory, if I have a gun, I want to shoot the TV, he said that Khmer people encroach Vietnamese territory for you to study again."

RFA could not be reached for comment by Minister in charge of Border Affairs Lam Chea on August 30.

In July, the Joint Committee on Border Affairs of the Council of Ministers issued a statement saying that the demarcation of the border between Cambodia and the Socialist Republic of Vietnam under the leadership of Prime Minister Hun Sen was correct, thorough, and clear to maintain Land area of Cambodia 181,035 as clearly defined in the Constitution.

Former CNRP lawmaker Oum Sam An explains that the government's demarcation of the border with Vietnam, not based on the French legacy or the 1873 Cambodian Cochinchina Convention, would result in the subsequent loss of some Khmer farmland and villages to Vietnam.

Mr. Oum Sam An says: "What was posted incorrectly in the past should be reviewed. Khmer villages and Khmer houses on Vietnamese soil should be reviewed by the Boundary Commission Secretariat. If not resolved, should appeal to the International Court of Justice to resolve the issue. In this regard, the President of the Cambodian Monitoring Council in Norway, Mr. Men Nath, suggested that Prime Minister Hun Manet should address this issue and the common concerns of the people to clean up the historical remnants left by his father."

Mr. Men Nath says: "The demarcation of the border was done by the Hun Sen government and based on the 1985 treaty, including making incorrect new maps according to the original map in Article 2 of the Constitution. According to law, it must be reviewed. "Even the prime minister must be punished with the same punishment as a crime or treason."

In November 2019, Hun Sen went to Hanoi to sign 84% of the border posts with the Vietnamese side.

The opposition considers the past border posts to be inconsistent with the legacy of French colonial rule and contrary to the 1991 Paris Peace Accords and the Cambodian Constitution.

# ពលរដ្ឋខេត្តត្បូងឃ្មុំស្នើរដ្ឋាភិបាលថ្មីដោះស្រាយដីស្រែនិងភូមិមួយចំនួនបាត់ទៅវៀតណាម ក្រោយបោះបង្គោលព្រំដែន

ពលរដ្ឋរស់នៅខេត្តត្បូងឃ្មុំអំពាវនាវឱ្យរដ្ឋាភិបាលអាណត្តិថ្មី ដោះស្រាយដីស្រែចម្ការ និងភូមិមួយចំនួនបានបាត់បង់ទៅវៀតណាម ក្រោយបោះបង្គោលព្រំដែនកាលពីពេលកន្លងទៅ។

ពលរដ្ឋទាំងនោះ ធ្លាប់លើកគ្នាតវ៉ា និងខឹងសម្បារនឹងមន្ត្រីជំនាញ ដែលបោះបង្គោលព្រំដែនចំកណ្ដាលដីស្រែចម្ការកេរឪពុកម្ដាយរបស់ពួកគាត់។

ពលរដ្ឋរាប់រយគ្រួសារ រស់នៅឃុំចាន់មូល ឃុំរូង និងឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅតែក្ដៅក្រហល់ក្រហាយក្នុងចិត្ត ពេលដែលពួកគាត់ នឹកឃើញរឿងរ៉ាវទាក់ទិនបញ្ហាព្រំដែនម្ដងៗ ដោយសារអ្នកភូមិទទួលរងនូវភាពអយុត្តិធម៌ជាច្រើន ករណីបាត់បង់ដីស្រែ បាត់បង់ភូមិកំណើត និងការគំរាមតាមប្រព័ន្ធតុលាការនៅពេលពួកគាត់តវ៉ាមិនពេញចិត្តនឹងអាជ្ញាធរកំណត់ខណ្ឌសីមាព្រំដែនជាមួយវៀតណាម កាលពីពេលកន្លងទៅ។

ក្រុមពលរដ្ឋទាំងនោះ តែងតែរក្សាភាពស្ងៀមស្ងាត់ និងអត់ធ្មត់ មិនហ៊ានបញ្ចេញមតិ និងតវ៉ាជុំវិញបញ្ហានេះនោះទេ ព្រោះខ្លាចអាជ្ញាធរចាប់ដាក់គុក និងធ្វើទុក្ខបុកម្នេញ។

ពលរដ្ឋរស់នៅឃុំចាន់មូល ស្រុកមេមត់ ខេត្តត្បូងឃ្មុំថ្លែងសុំមិនបញ្ចេញឈ្មោះ ប្រាប់វិទ្យុអាស៊ីសេរីថា អាជ្ញាធរអូសបន្លាយពេលមិនដោះស្រាយវិវាទដីធ្លីរបស់ពលរដ្ឋរស់នៅតាមបណ្ដោយព្រំដែនដែលត្អូញត្អែរបាត់បង់ដីស្រែចម្ការកេរឪពុកម្ដាយទៅវៀតណាម បន្ទាប់ពីបោះបង្គោលព្រំដែន។

លោកស្រីថា តំបន់ដែលបាត់បង់ដីស្រែទៅវៀតណាមតាមបណ្ដោយព្រំដែនបិតក្នុងឃុំរូង ឃុំជាំ ឃុំចាន់មូល ឃុំទ្រៀក និងឃុំជាំក្រវៀន។

ពលរដ្ឋលាក់ឈ្មោះ៖ «សោកស្ដាយមិនដឹងធ្វើម៉េច? ឱ្យតែហ៊ានហាមាត់ គុកមួយមាត់គុក។ ខ្ញុំចង់សំណូមពរឱ្យគាត់ (លោក ហ៊ុន ម៉ាណែត) មើលព្រំដែនស្រួលបួល កុំឱ្យដល់ឪដល់កូន»។

អ្នកភូមិអះអាងថា ពលរដ្ឋរស់នៅតំបន់ព្រំដែន ខ្វះភាពកក់ក្ដៅ មិនត្រឹមតែបាត់បង់ដីស្រែកេរដូនតានោះទេ បែរជាក្លាយជាជនរងគ្រោះជាប់បណ្ដឹងនៅតុលាការ ហើយមកទល់ពេលនេះមានពលរដ្ឋយ៉ាងហោចណាស់ ៦នាក់ ជាប់បណ្ដឹងនៅតុលាការដោយសារតវ៉ាទាមទារដីស្រែចម្ការដែលបាត់បង់ទៅវៀតណាម។



លោកនាយករដ្ឋមន្ត្រីថ្មី ហ៊ុន ម៉ាណែត

រីឯពលរដ្ឋភាគច្រើនបានបោះបង់ដីដែលវៀតណាមរំលោភយក ព្រោះមិនចង់មានរឿងវែងឆ្ងាយ ហើយមិនចង់ចំណាយពេលដើរប្ដឹងផ្ដល់នោះឡើយ។

ដីស្រែចម្ការរបស់អ្នកភូមិចាន់មូលតាមបណ្ដោយព្រំដែន នៅចំណុចភូមិចាន់មូលសរុបជាង ៣០០ ហិកតារ ដែលវៀតណាមគ្រប់គ្រងតាំងពីឆ្នាំ១៩៩៨ រដ្ឋាភិបាលបានសម្របសម្រួល បោះបង្គោលព្រំដែនជាមួយភាគីវៀតណាមរួចរាល់ ភាគីវៀតណាមបានប្រគល់ដីនៅតំបន់នោះមួយផ្នែក ដែលមានទំហំជាង ៧០ ហិកតារប៉ុណ្ណោះឱ្យអាជ្ញាធរខ្មែរវិញ។

អ្នកស្រុកអះអាងទៀតថា ភូមិចាន់សាលា បិតនៅចំណុចវាលត្បូង ដែលជាភូមិបុរាណមួយ ពលរដ្ឋខ្មែររស់នៅទីនោះច្រើនជំនាន់មកហើយ បច្ចុប្បន្នបានក្លាយជាវាលរហោឋាន គ្រប់គ្រងដោយវៀតណាម។

រីឯនៅភូមិតានង ក្នុងឃុំចាន់មូល បិតនៅចន្លោះបង្គោលព្រំដែនលេខ ៩៧ រហូតដល់៩៩ មានដីស្រែជាច្រើនហិកតារ

**តទៅទំព័រទី២២**

# After Border Post Demarcation Tbong Khmum Residents Claim...

View of border post 95 in Cheung village, Choam commune, Memot district, Tbong Khmum province

September 2, 2023.

Many families living in Memot district, Tbong Khmum province, still enjoy and cultivate on the land of their parents who lost to Vietnam after the border post was demarcated.

They claim that Cambodian and Vietnamese authorities have been stepping up border posts in the area in secret as Cambodia is spreading Covid-19 and a political crisis.

For more than three years now, since 2020, when Cambodians have been concerned about the spread of Covid-19, the Cambodian-Vietnamese government has been speeding up the demarcation of secret border posts in Tbong Khmum province.

Residents claim that the areas where the Cambodian and Vietnamese authorities set up the border post is in Tonlong commune, Choam Kravien commune, Choam commune, Chan Moul commune and Dar commune, Memot district, between border post 95 to post 98.

Most people are not aware of this, and when they see a border post thrown in the middle of their ancestral farmland, some are shocked, some are crying, and some are silent, worried, afraid to protest, afraid of the authorities to mistreat and sue them to courts.

Villagers say that between border post 95 in Cheung village, Choam commune, Memot district, after the border post was demarcated, Vietnamese authorities hastened the construction of a border belt/ring road everywhere, causing hundreds of hectares of Cambodian farmland to be lost to Vietnam.

Resident of Memot district, speaking on condition of anonymity, told RFA that many families in the village are now brave enough to harvest coconuts, mangoes, and durians on Vietnamese-occupied land.

He stated that the people do not like the incorrect and hidden border posts.

Citizens ask to remain anonymous say: After building a "belt/ring road, some mango plantations on the south side of the road belong to the Vietnamese. But our Cambodian people in Cheung Duren village, are still growing and their ancestors are in Chrong. I believe that in the future there will be more problems with the land."

Residents claim that Ampul and Kro oub villages (nicknamed Phok villages) in Chan Moul commune, home to thousands of Cambodian families since ancient times, have been completely taken over by Vietnam.

These villages have hundreds of ancient Khmer houses and old homes of Khmer ancestors, and Vietnamese authorities blocked them from learning the Khmer script after the Cambodian government signed a 1985 treaty demarcating the state border.

Cambodians living in these villages are still sending their children to learn the Khmer language in Cambodian territory near the border in Tbong Khmum province.

These villages, although occupied by the Vietnamese, were able to cross the border into Cambodian territory normally, but after the border posts were demarcated and the border belt/ring road was built, the Vietnamese authorities did not allow them to enter and leave Cambodia freely.

The villagers added that after the Cambodian and Vietnamese authorities set up border posts in Memot and Ponhea Krek districts in Tbong Khmum province, they often protested and complained to the authorities to help resolve their farmland, but nothing settle.

The territory of Ampul village stretches to Sre Tanong pagoda, and the Cambodian and Vietnamese authorities have agreed to set up border posts and build a border belt road next to the pagoda fence.

In addition, after the border posts were demarcated, the Vietnamese authorities tightened their grip and built border crossings in all directions, even

**Please see /22**

អត្ថបទ បញ្ចេញមតិ

# ខ្មែរ ឆ្លាតឡើង!

## ខ្មែរ ឆ្លាតជាង យួន មែនទេ?

យួន សត្រូវរបស់អាមេរិច ក្លាយជាមិត្តហើយ បែរអាមេរិចមិនដែលមានកូនចិត្ត ធ្វើបាប កម្ពុជាសោះ កម្ពុជា បាន ធ្វើអោយអាមេរិច ខឹងសប្បារ ម្តងហើយម្តងទៀត។

អាមេរិច និង វៀតណាម ដែលខ្មែរ ហៅថា "យួន" នឹងចុះហត្ថលេខា លើកិច្ចព្រមព្រៀងជាដៃគូរយុទ្ធសាស្ត្រ ដើម្បីរឹតបណ្តឹង ចំណងមិត្តភាពបន្ថែម នៅពាក់កណ្តាលខែកញ្ញា 2023 នេះហើយ។

លោក ជោ បាយឌិន ប្រធានាធិបតីអាមេរិច នឹងចេញដំណើរពីប្រទេសឥណ្ឌា ទៅចុះទស្សនៈកិច្ច ជាផ្លូវរដ្ឋ នៅប្រទេសយួន នៅសប្តាហ៍ទី2ខាងមុខនេះ ដោយយោងតាម ការសែត រ៉យទ័រ ចុះផ្សាយ កាលពីថ្ងៃទី 29 សីហា 2023។

ហើយនៅក្នុងពេលធ្វើទស្សនៈកិច្ចនោះ លោក បាយឌិន និងមន្ត្រីយួន នឹងពិភាក្សារស៊ីជម្រៅ ដោយផ្តោតទៅលើការពង្រីកវិស័យបច្ចេកវិទ្យាទំនើប និងវិស័យសេដ្ឋកិច្ច រវាង អាមេរិច និងយួន។

យួន កំពុងលួងអាមេរិចបានហើយ ព្រោះយួនដឹងច្បាស់ណាស់ ចិន និងអាមេរិច កំពុងជាសត្រូវស្លាប់រស់ នឹងគ្នាដូច កាល សង្គ្រាម យួន និងអាមេរិច អញ្ចឹង។យួនចេះឆ្លៀតឱកាសយកចំណេញពេល ចិន និងអាមេរិច កំពុង ឈ្លោះគ្នា។

ពេលយួនមានជម្លោះសង្គ្រាមជាមួយអាមេរិច បែរជាយួនចេះរកប្រទេសជាប់ភូមិផងរបងជាមួយ អោយទទួលរងគ្រោះជំនួសជាមួយដែរ ។

មេដឹកនាំប្រទេសនោះ ចូលចិត្តធ្វើជា ចិត្តល្អមហាសាល ប្រៀបដូចរឿងតាជូជក់អញ្ចឹង អោយកូនទៅធ្វើ ខ្ញុំបំរើតាជូជក់ ព្រោះចង់បានអំណាចត្រាស់ជា ព្រះឥន្ទ។

ដោយឡែ កម្ពុជា មិនដែល មានជម្លោះអ្វី ជាមួយ អាមេរិច បន្តិចណាសោះ បែរជា ធ្វើអោយអាមេរិច ខឹងសប្បារ ។ រឿង យួន និងអាមេរិច សោះក៏បានធ្វើអោយ អាមេរិច ដេញទម្លាក់គ្រាប់បែកយួនរហូតចូលដល់ដីស្រុកខ្មែរ។ វាជារឿងពិត!

ចាស់ពីដើមឧស្សាហ៍និយាយថា ពូជខ្មែរ ជាពូជពូកែច្បាំង ឬពូជអ្នកចម្បាំង ហើយច្បាំងរហូត អស់ទឹកដី។ មិនដឹងថា ជាពូជខ្មែរចម្បាំង ឬពូជចម្ប៉ារចម្បាំងនោះទេ? ពីព្រោះ ចម្ប៉ារចូលចិត្តធ្វើសង្គ្រាម រហូតអស់ទឹកដី។

យួនមិនសូវចេះច្បាំងទេ។ តែអោយយួនមានបញ្ហារ ច្បាំងគ្នា យួន ចេះទៅរក អ្នកពូកែច្បាំង អោយមកជួយ រកទុក្ខជំនួស ។ ដល់ពេល អ្នកពូកែច្បាំង អស់កំលាំង យួន យកទឹកដីបន្ថែម។

គិតមើលបន្តិចទៅ!

ឥឡូវ ចិន រៀនតាម យួន គឺ ទៅរកអ្នកពូកែច្បាំង ឬពូជអ្នកចម្បាំងមករងទុក្ខជំនួស ទុកជាមុន។ ជាថ្មីម្តងទៀត រឿង អាមេរិច និង ចិនសោះ បែរ កម្ពុជា បាន ធ្វើអោយ អាមេរិច អាក់អន់ស្រពន់ចិត្ត មានភាពសង្ស័យ លើមូលដ្ឋានទ័ពជើងទឹកសមុទ្ររាម ក្រោមការប្រើប្រាស់របស់ចិន ។

វាកំពុងកើតមានឡើង!

រីឯចំណែកយួន រង់ចាំឱកាសល្អ ហើយពេលឱកាសចំណេញមកដល់ គឺពង្រីកទឹកដីបន្ថែមបន្តិចម្តង បន្តិចម្តង។ យួន ប្រៀបដូច តាជូជក់អញ្ចឹង ប៉ន្តែ យួន ខុសពី តាជូជក់ គឺស៊ីច្រើនយ៉ាងណា ក៏មិនចេះបែកពោះដែរ។

កុំអួតពីរឿង ប្តឹងតុលាការអន្តរជាតិ អោយជួយ នៅពេលនោះ ។ បើមិនចេះជួយខ្លួនឯងពីឥឡូវទេ សម្បីតុលាការអន្តរជាតិ ក៏ពិបាកជួយ ពីក្តីដណ្តើម ឬឈ្លានពានយកទឹកដីប្រទេសជិតខាង នៅពេលនោះដែរ។ យួនចេះតែមានបាន ទៅមុខទៀតហើយ។នោះគឺដូចកោះត្រល់ជាដើម។

ឯកូនៗ ព្រះវេសណ្តារ ដែលចង់

**តទៅទំព័រទី២២**

opinion

# Khmer is smart!

## Khmer is smarter than Vietnamese, right?

Vietnam, the enemy of the United States, became a friend, and the United States never had the heart to harm Cambodia, Cambodia has repeatedly angered the United States again and again.

The United States and Vietnam, which Cambodia calls “Yuan”, will sign a Strategic Partnership Agreement to further strengthen ties by mid-September 2023.

US President Joe Biden will leave India for a state visit to Vietnam in two weeks, according to Reuters published on August 29, 2023.

During the visit, Biden and Vietnamese officials will have in-depth discussions focusing on the expansion of modern technology and the economic sector between the United States and Vietnam.

Vietnam is already comforting the United States because Vietnam knows very well that China and the United States are live and dead enemies, just like during the Vietnam-US war. Vietnam seizes the opportunity when China and the United States are at conflicts.

When Vietnam was at war with the United States, Vietnam was able to find a neighboring country with a fence to suffer instead.

The leader of that country likes to be very kind, like the story of Ta Chu Chuk, so he (Budha) sent his sons to be slave of Ta Chu Chuk because he wanted the power of enlightenment as Indra.

Cambodia has never had any conflict with the United States at all, it has angered the United States. The story of Vietnam and the United States also made the United States dropped bombs on Vietnam until they reached Cambodian territory. It's true!

The elderly mostly said that the Khmer race is good at fighting or warriors and fights until nearly finish of land. Don't know if it was a Khmer warrior race or a warrior of Champa? Because Champa likes to make war until it runs out of territory.

Vietnam is not good at fighting. But for the Vietnamese to have a war problem, the Vietnamese know how to go to the best fighters to come and help them instead. When you are tired of fighting, Vietnam will take more territory. Think about it!

Now the Chinese learn from the Vietnamese to go to the best warriors or warriors to suffer instead. Once again, the story of the United States and China, instead of Cambodia, made the United States dissatisfied and suspicious of the Ream naval base under Chinese use. It is happening!

Vietnam, on the other hand, is waiting for a good opportunity and when the opportunity to profit comes, it will gradually expand its territory. Vietnam is like Ta Chu Chuk, but Vietnam is different from Ta Chu Chok, he eats a lot and does not know how to lose weight.

Do not brag about suing to the International Court of Justice at the time. If you do not know how to help yourself now, even the International Court of Justice will have a hard time helping to seize or invade neighboring countries at that time. Vietnam has always been able to move forward. That is like Koh Tral.

As for the children of Budha who want to become enlightened, they will become slaves of all Ta Chu Chuk, like Kampuchea Krom, being persecuted by Vietnam like now. So just wait for going to die (Chet Roy)!

Now American investors are all billionaires. So American investors and companies will go from China to Vietnam. Vietnam's labor force in the manufacturing industry is cheap. Vietnam is still smart!

So far, Cambodia has not been able to import even preferential tariffs on imports to the United States. Cambodian workers lose their jobs! The new Minister of Labor sings karaoke and there are people standing behind him! Maybe the Minister of Labor is so upset!

**Please see /22**

តមកពីទំព័រទី ០៦

# ស្គាល់ស្តេចឆាលទី៣ នៃចក្រភព

គ្រប់គ្រងជា«ព្រះអង្គម្ចាស់រាជទាយាទ ប្រទេសអេកូស ។ ព្រះបិតាព្រះនាម ព្រះអង្គម្ចាស់ ហ្វីលីព ដែលមានឋានៈជាឌុចអេឌីនប៊ឺគ ។ ព្រះអង្គម្ចាស់ឆាល ជានាយទាហ៊ាន ណេវី (ជើងទឹក) បានរៀបអភិសេកជាមួយមហេសីមុនព្រះនាងដាយ៉ាណា មានបុត្រា២ព្រះអង្គ គឺព្រះអង្គម្ចាស់វីលាមនឹង ព្រះអង្គម្ចាស់ហារី, តែជាមួយមហេសីក្រោយ ព្រះមហេសីកាម៉េឡា មិនមានព្រះរាជបុត្រទេ។ ប្រសិនបើ ព្រះអង្គម្ចាស់វីលាម មិនបានឡើងគ្រងរាជ្យបន្តរដោយប្រការណាមួយទេនោះ ពុំមែនទ្រង់ហារី ជាព្រះរាជទាយាទទេ តែព្រះរាជបុត្រច្បងនៃទ្រង់វិលាម ទេ ដែលនឹងឡើងជារាជទាយាទទៅវិញ នេះជាអត្ថន័យរបស់រដ្ឋធម្មនុញ្ញអង់គ្លេស ។

ឆាលទី៣ សោយរាជ្យលើប្រទេសណាខ្លះ?

គឺមិនមែនតែ«ចក្រភពអង់គ្លេស»តែមួយទេ! គឺនៅលើ«រាជាណាចក្រខម៉ន់វៀល»ដែលមានប្រទេសបួនដាច់ពីគ្នាផ្សេងទៀត។ គួរដឹងថា ឆាលទី៣ បន្តររាជ្យពី អេលិសាបេតទី២ ដែលនៅចុងបញ្ចប់ជីវិតរបស់ព្រះអង្គទ្រង់គ្រងរាជ្យជាស្តេចរបស់ ចក្រភពអង់គ្លេសផង (ដែលចែកជា អង់គ្លេស ប្រទេសគ្គាល ប្រទេសអៀឡង់ខាងជើង នឹងប្រទេសអេកូស) បូករួមទាំងប្រទេសខូម៉ុនវៀល (ប្រទេសសម្បត្តរួម) ធំៗផ្សេងទៀត ដូចជា ប្រទេសអូស្ត្រាលីផង ប្រទេសកាណាដាផង ប្រទេសនូវែលហ្សេឡង់ផង នឹងប្រទេសអាហ្វ្រិក១៤ផ្សេងទៀត, ប្រទេសទាំងនោះ ទទួលស្គាល់ថា ស្តេចឆាលទី៣ ជាប្រមុខរដ្ឋរបស់ពួកគេ ប្រទេសទាំងនោះដូចជា ពាហាម៉ាស អង់ទីគ្គានឹង បាប៊ូដា ឬ បែលីស ។ល។ គួររំលឹកថា ក្នុងរយៈពេលគ្រងរាជ្យ៧០ឆ្នាំរបស់ អេលិសាបេតទី២ មានការហូរហៀនឹងចេញចូលនៃប្រទេសប្រមាណ៧០ ពី«រាជាណាចក្រខូម៉ន់វៀល» ដោយសារនៅពេលបានឯករាជ្យ ប្រទេសខ្លះនោះ គេបានជ្រើសយកនយោបាយ ឯករាជ្យបែបសាធារណរដ្ឋនិយម ដូច្នេះគេត្រូវចាកចេញខម៉ន់វៀល ។

ស្តេចឆាលទី៣ បានធ្វើសច្ចាប្រណិធានអ្វីខ្លះ?

នៅមុនពេលពាក់ម្កុដរាជ្យ ស្តេចឆាលទី៣ បានធ្វើសច្ចាប្រណិធាន នៅចំពោះមុខព្រះ នៃវិហារអង់គ្លីខាន់ នឹងវិហារប្រូតេស្តង់អេកូស ថា«ព្រះអង្គនឹងគ្រប់គ្រងប្រជារាស្ត្រប្រកបដោយភាពយុត្តិធម៌នឹងអំណរគុណ» ហើយនឹងបន្ថែមថា «ខំប្រឹងប្រែងគ្រប់គ្រង ឲ្យបានប្រសើរ ដូចព្រះមាតារបស់ព្រះអង្គ...» ។ នៅក្នុងរជ្ជកាល អេលីសាបេតទី២ រាជានិយមនៃចក្រភាពអង់គ្លេស មានប្រជាប្រិយភាពលើសាកលលោកខ្លាំងណាស់ តែស្តេចឆាលទី៣ ក៏បានបិតនៅគ្រប់ជំហ៊ាន តាមជាប់ជាមួយសកម្មភាពបំរើជាតិ ព្រះមាតាជានិច្ចផងដែរ, ព្រះអង្គជាព្រះប្រមុខរដ្ឋ តែមិនធ្វើនយោបាយទេ ។ តួរនាទីនយោបាយក្នុងនឹងក្រៅប្រទេស ជាភារៈកិច្ចរបស់នាយករដ្ឋមន្ត្រី ទៅវិញទេ។

ចក្រភពអង់គ្លេស ថ្វីត្បិតតែមានទំហំតូចមែនពិត តែទំនាក់ទំនងប្រទេសតាមរយៈរាជាណាចក្រខម៉ន់វៀល ព្រះមហាក្សត្ររបស់ប្រទេសមួយនេះ មានអំណាចនឹងកម្លាំងទំហំធំធេងណាស់ ៕

KhmerPost USA, LLC
សារព័ត៌មានខ្មែរបុសសហរដ្ឋអាមេរិក



អគ្គនាយក សុបិន្ទ អ៊ុង
Soben Ung, Co-Founder|Publisher
Cell: 978-656-8141
Soben@khmerpostusa.com

The KhmerPost USA is a free Monthly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes Once a month from Lowell, Massachusetts.

ច្នៃសោភ័ណ្ឌភាព Design Artist Heng Chhun Leng

Article Submission Khmerpostusa@gmail.com

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

ពេទ្យចាប់សរសៃ វេជ្ជ. Hai N. Huynh
Chiro Health & Rehab, Inc.



ប្រសិនបើលោកអ្នកមានរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍ សូមអញ្ជើញមក Chiro Health & Rehab សម្រាប់ការវាយតម្លៃ និងព្យាបាលរបួសឲ្យជាសះស្បើយ។ថ្វីបើជាក់ហុសអ្វីក៏ដោយលោកអ្នក ត្រូវបានធានារ៉ាប់រង ។ គ្មានការចំណាយពីហោប៉ៅរបស់លោកអ្នកទេ។ការិយាល័យរបស់យើងមានបំពាក់គ្រឿងប្រិក្ខាល្អៗ និងវេជ្ជបណ្ឌិត Dr. Huynh មានបទពិសោធន៍ជាង២០ឆ្នាំ ក្នុងការព្យាបាលរបួសដោយគ្រោះថ្នាក់ចរាចរណ៍។ជំងឺដែលយើងធ្វើការព្យាបាល មានដូចខាងក្រោម:

ម៉ោងធ្វើការ: ថ្ងៃច័ន្ទ ដល់ សុក្រ
០៩:០០ ព្រឹក -០៩:០០ល្ងាច
០១:០០ យប់-០២:០០រសៀលបិទ-អាហារថ្ងៃត្រង់
ការណាត់ជួបរៀងរាល់ថ្ងៃសៅរ៍

• ឈឺក • ឈឺខ្នង • ឈឺស្មា • ឈឺសាច់ដុំ • ឈឺក្បាល
• គ្រិចផ្លោះ • subluxation • ឈឺឆ្អឹងខ្នង
• sciatica • របួសដោយការទាយទ៉ាត់
• ជំងឺសន្លាក់ • របួតឌីស • រលាកសរសៃប្រសាទ
• ថែទាំសុខភាពរាងកាយ



ផ្លូវ 6 Pine Street Lowell, MA 01851
ទូរស័ព្ទលេខ (978) 221-6449 ហ្វាក៖ (978) 710-4185

ធ្វើការណាត់ជួបក្នុងថ្ងៃតែមួយ សម្រាប់អ្នកជំងឺថ្មី
Chiro Health & Rehab, Inc.

# Do you know King Charles III of the United Kingdom?

From Page 06

Elizabeth II, there was an influx of about 70 countries from the "Commonwealth Kingdom", because some countries, when they gained independence, opted for an independent republican policy, so they had to leave commonwealth without a king.

What oaths did King Charles III make?

Before wearing the crown, King the monarchy of the United Kingdom was very popular all over the world, but King Charles III was also at every step, following the patriotic activities of his mother, he was the head. The King does not do politics. Political roles at home and abroad are the responsibility of the Prime Minister.

The United Kingdom, despite its small size, has a great deal of power and influence through its monarchy. Al-



Charles III swore before the gods of the Anglican Church and the Protestant Church that "he would rule the people with justice and gratitude" and would add "will strive to rule to be as good as his mother ..."

During the reign of Elizabeth II, though Britain is a real monarchy, it has its own political institution, a democracy, meaning that all succession to power is elected, except for the monarchy. The family power of the royal family has not changed since the past.

MILL CITY GROWS
MOBILE Market
2023 MARKET SCHEDULE
Lowell, Massachusetts
MillCityGrows.org | 978-455-2620

TUESDAYS NEW TIME!
10am - 1pm
Lowell Community Health Center
161 Jackson Street
through October 31

THURSDAYS
9am - 12pm
Lowell Senior Center Parking Lot
276 Broadway Street
through November 2

WEDNESDAYS
10am - 12pm
Central Food Ministry, Inc.
370 W. 6th Street
through November 1
&
2pm - 4pm
Lowell General Hospital
Main Campus
295 Varnum Avenue
through November 1

FRIDAYS
11am - 2pm
NEW MARKET!
Lowell Farmers Market
350A Dutton Street
(Bi-weekly)
July 7 & 21 • August 4 & 18
September 1, 15, & 29
October 13 & 27
&
NEW TIME!
3pm - 5pm
Fortune and Flame Sweet Bar
500 Pawtucket Street
through November 3

We accept SNAP/EBT, HIP, WIC and Senior Farmers Market Coupons, cash, credit, debit, and Apple Pay!

Thank you to our Mobile Market supporters!
MDAR USDA
Cummings Foundation
PGI
TuftsMedicine Lowell General Hospital
SNAP Supplemental Nutrition Assistance Program

យើងជឿថា ឆ្នាំល្អបំផុតរបស់អ្នកមកដល់ហើយ
(ឆ្នាំកន្លងទៅ ក៏ល្អសម្រាប់អ្នកដែរ)



Element Care PACE ជួយអ្នកឱ្យរស់នៅដោយឯករាជ្យនៅក្នុងសហគមន៍។
• ការថែទាំសុខភាពតាមបែបវេជ្ជសាស្ត្រ ថែទាំធ្មេញ និងថែទាំភ្នែកផ្ទាល់ខ្លួន ។
• មជ្ឈមណ្ឌលបើកបម្រើនៅពេលថ្ងៃ
មានការដឹកជញ្ជូន មានអាហារ និងសកម្មភាពសង្គម
ទាំងអស់នេះ អ្នកក៏អាចរក្សាសុខភាពល្អបំផុត។
Element Care | PACE
ស្វែងយល់បន្ថែម តើអ្នកឬមនុស្សជាទីស្រឡាញ់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរឬទេ៖
(877) 803-5564 (TTY 711) ElementCare.org
មិនគិតថ្លៃសម្រាប់អ្នកមានសិទ្ធិទទួលបាន MassHealth និង Medicare ។ សូមទាក់ទងមកយើងសម្រាប់តែ Medicare និងជម្រើសបង់ប្រាក់ដោយខ្លួនឯង។
អ្នកចូលរួមទទួលបានការថែទាំសុខភាពទាំងអស់ សេវាពេទ្យបឋម និងពេទ្យឯកទេស - និងសេវាសង្គ្រោះបន្ទាន់ផ្សេងទៀត ដែលអនុញ្ញាតដោយ PACE ឬទទួលខុសត្រូវទាំងស្រុង និងផ្ទាល់ខ្លួនចំពោះថ្លៃសេវាដែលគ្មានការអនុញ្ញាត។

Eastern
PHYSICAL THERAPY

ឈឺចុកចាប់មែនទេ ?
យើងអាចជួយបាន៖
- របួសដោយសារគ្រោះថ្នាក់ចរាចរណ៍
- រអិល និងដួល
- ជំងឺរលាកសន្លាក់រ៉ាំរ៉ៃ
- ស្តារនីតិសម្បទា
- ព្យាបាលដោយការម៉ាស្សា
- ព្យាបាលបន្ទាប់ពី ការវះកាត់ឆ្អឹង និងមិនវះកាត់
- សំណងនៃការស្តារនីតិសម្បទាកម្មករ (Worker's Comp Rehab)

យើងផ្តល់សេវាបង្ការសុខភាព និងស្តារនីតិសម្បទាដោយអ្នកជំនាញសុខាភិបាលដែលមានអាជ្ញាប័ណ្ណ។ យើងប្រើបច្ចេកទេស/ឧបករណ៍ហាត់ប្រាណ ឬការលាតសន្ទឹងសណ្តូក ដើម្បីជួយសម្រាលការឈឺចាប់ ឬជាសះស្បើយពីរបួស ឬការវះកាត់ និងបង្កើនសមត្ថភាពរាងកាយទាំងមូល។

Have Aches & Pain?
We Can Help.
- Injuries from Auto Accident
- Slip & Fall
- Chronic Arthritis
- Physical rehabilitation
- Massage Treatment
- Post Orthopedic Surgical and Non-Surgical
- Worker's Comp Rehab

We provide preventative and rehabilitative health services by licensed health professionals. We use exercise or stretching techniques/equipments to help relief pain or recover from injuries or surgeries and improve overall physical ability.

Eastern Physicial Therapy
851 Middlesex Street, Suite 1 Lowell, MA 01851
Phone: 978-677-6333 Fax: 978-677-6982

តមកពីទំព័រទី ១៨

# ខ្មែរ ឆ្លាត ជាងយួន មែនទេ?

ត្រាស់ជា ព្រះឥន្ទ នឹងក្លាយ ខ្ញុំបំរើរបស់តាជូជក់ទាំងអស់ ដូចកម្ពុជាក្រោម កំពុងត្រូវយួន ធ្វើបាប ដូចពេលនេះ។ អញ្ជឹង មានតែរង់ចាំ ចេតរ៉យ ហើយ!

ពេលនេះ អ្នកវិនិយោគទុនអាមេរិចសុទ្ធតែមហាសេដ្ឋី គ្រាក់ៗ។ អញ្ជឹង អ្នកវិយោគទុន និងក្រុមហ៊ុន អាមេរិច និងចេញពីចិន ទៅយួនវិញ ។ កំលាំងពលកម្មនៅប្រទេសយួន ក្នុងវិស័យឧស្សាហ៍កម្មផលិតកម្ម ស្ថិតក្នុងតម្លៃថោក។ យួនឆ្លាតដដែល!

មកដល់ពេលនេះ សូម្បីពន្ធអនុគ្រោះនាំទិញចូល អាមេរិច ក៏កម្ពុជាយកអត់បាន។ កម្មករខ្មែរ បាត់បង់ការងារ!រដ្ឋមន្រ្តីការងារថ្មី ច្រៀងការ៉ាអូខេ ហើយមានអ្នកឈរពីក្រោយអមទៀត! ប្រហែលរដ្ឋមន្រ្តីការងារនោះ ពិបាកចិត្តខ្លាំងពេក!

យួនពង្រីកទឹកដី ពីប្រទេសដៃវៀតតូចមួយ មកយកចម្ប៉ារ បានទាំងស្រុង ចម្ប៉ារបាត់ឈ្មោះ ពីផែនទីសកល ហើយនៅសល់តែផែនទីប្រវត្តិសាស្រ្ត។

យួន យកចិត្តបារាំង ។ បារាំងបាក់ចិត្ត លើយួន ហើយបារាំង បានកាត់ទឹកដីកខ្មែរក្រោម អោយយួន ដោយអតនោម័ត។ កម្ពុជាក្រោមបាត់ឈ្មោះពីផែនទី តែនៅមាន អត្តសញ្ញាណ ភាសារខ្មែរ និងវប្បធម៌ខ្មែរ ជួយសំគាល់។ ពិតជាកំសត់ហើយ!

អញ្ជឹង ហើយបាន បារាំងថា យួនឆ្លាតជាងខ្មែរ!

ឥឡូវ យួនមានទំហំដីកាន់តែធំ ហើយប្រជាជនកាន់តែច្រើន។ យួន ប្តូរយុទ្ធសាស្រ្តបន្តិចពង្រីកសេដ្ឋកិច្ចប្រទេសយួន ក្នុងពេល ប្រទេសចិន កំពុងបាត់ម្ចាស់ការ លើការពង្រឹងសេដ្ឋកិច្ចខ្លួន។

កម្ពុជា នៅសល់កណ្តាលបន្តិចហ្នឹងទេ។ ទីប្រឹក្សារមួយចំនួន និយាយខ្មែរប៉ែឡាំងៗ ហើយអាណត្តិទី7 នេះ យួនចេញមុខ បង្ករអំពើហឹង្សារ ចេញមុខជាសាធារណៈទៀត។ ពួកយួន ថ្លើមធំលែងខ្លាចខ្មែរម្ចាស់ស្រុកហើយ។ ទើបកើតឡើងក្តៅៗនេះទេ។

មានតែក្លាហានឡើង ប្តូររបៀបគិតទម្លាប់ចាស់ និងរបៀបប្រព្រឹត្ត ចៀសវាងដើរតាម ដានអតីតកាល ពេលនោះនឹងជួប ភាពមានបាន និង ភាពសប្បុរសប្បាយ ភាពរុងរឿង ដល់ប្រទេសជាតិ និងប្រជាជន។ ខ្មែរ ឆ្លាតឡើង!

# Khmer is smarter than Vietnamese, right?

From Page 18

Vietnam expanded its territory from a small Vietnamese country to completely capture Champa, Champa lost its name from the global map and only the historical map remained.

Vietnam favors France. France was heartbroken over Vietnam and France cut off Khmer Krom territory to Vietnam arbitrarily. Kampuchea Krom lost its name on the map, but still has its Khmer language identity and Khmer culture. Really so sad!

The French said that Vietnamese is smarter than Cambodian!

Vietnam now has a larger land area and a larger population. Vietnam changes strategy slightly to expand Vietnam's economy at a time when China is losing control of its economy.

Cambodia remains its middle land. Some advisers speak Khmer not clearly and fluently, and in this seventh mandate, Vietnamese came forward to cause more violence in public. The Vietnamese with big livers are no longer afraid of the Khmer people who own the country. It is just recently.

Be encouraged to change your way of thinking, old habits, and practices, avoid following the past, then you will meet the wealth and prosperity of the nation and its people. Khmer is smart!

AccuCare
Home Care Agency
ភ្នាក់ងារថែទាំអ្នកជំងឺតាមផ្ទះ
Group Adults Foster Care Program
កម្មវិធីថែទាំមនុស្សពេញវ័យ
144 Merrimack Street • Suite 404
Lowell, MA 01852 • 617-783-7177

Open for enrollment.
Persons with disability and chronic illnesses at no cost to patients.
We provide an individual care plan developed by a registered nurse and case manager.
Service plan includes medication management, personal care service at home, a Nurse and Case Manager monitoring ongoing needs.
Patient must have Masshealth Standard to qualify.
We accept United, Senior Whole Health, Fallon and Commonwealth Care Alliance.



បើកទទួលចុះឈ្មោះ
ជនមានពិការភាព និងអ្នកជំងឺរ៉ាំរ៉ៃ ដោយឥតគិតថ្លៃ។
យើងផ្តល់ផែនការថែទាំអ្នកជំងឺជាបុគ្គលដោយគិលានុបដ្ឋាយិកាដែលមានចុះបញ្ជីត្រឹមត្រូវ និងគ្រូពេទ្យគ្រប់គ្រងអ្នកជំងឺ។
ផែនការសេវាកម្មរួមមាន ការគ្រប់គ្រងឪសថ សេវាថែទាំដោយផ្ទាល់តាមផ្ទះ គិលានុបដ្ឋាយិកា
និងគ្រូពេទ្យគ្រប់គ្រងអ្នកជំងឺពិនិត្យតាមដានជាប្រចាំតាមតម្រូវការ។
ដើម្បីមានលក្ខណៈគ្រប់គ្រាន់ អ្នកជំងឺត្រូវតែមាន Masshealth Standard ។
យើងទទួល United, Senior Whole Health, Fallon
និង Commonwealth Care Alliance ។

តមកពីទំព័រទី ០៦

# ពលរដ្ឋខេត្តត្បូងឃ្មុំស្នើរដ្ឋាភិបាល

ត្រូវវៀតណាមគ្រប់គ្រងដោយមានបង្គោលព្រំដែនខ្លះបោះចំកណ្តាលដីស្រែអ្នកភូមិ។

លើសពីនេះទៀត ភូមិអំផុល និងភូមិភោគ ដែលជាភូមិដ៏ចំណាស់ ឋិតក្នុងឃុំចាន់មូល បច្ចុប្បន្នក៏ត្រូវបានវៀតណាមកាន់កាប់ដែរ ក្រោយពីរដ្ឋាភិបាលបោះបង្គោលព្រំដែនជាមួយវៀតណាមរួចរាល់ចាប់តាំងពីឆ្នាំ២០១០ រហូតដល់ឆ្នាំ២០២២។ រីឯក្រសួងមហាផ្ទៃបានលុបឈ្មោះភូមិទាំងនេះចេញពីបញ្ជីគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់។

កន្លងទៅអ្នកភូមិតែងតែចួបជុំគ្នានិយាយដើមមន្ត្រីគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ដែលចុះទៅពន្យល់ពួកគាត់ ឱ្យទទួលយកការកំណត់ខណ្ឌសីមា ដែលពួកគាត់ចោទប្រកាន់ថា ធ្វើឱ្យបាត់បង់ដីស្រែចម្ការរបស់ពលរដ្ឋខ្មែររាប់រយគ្រួសារ។

ពលរដ្ឋម្នាក់ឈ្មោះ ឆាយ វិត បានថ្លែងជាសាធារណៈផ្តាំទៅអតីតទេសរដ្ឋមន្ត្រីនៃគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន លោក វ៉ា គឹមហុង ថា ភូមិអំផុល និងភូមិភោគ មិនមែនបាត់បង់នៅសម័យដូនតាខ្មែរនោះទេ គឺបាត់ក្នុងសម័យនេះ។

ឆាយ វិត៖ «គណៈកម្មាធិការព្រំដែនគេមកដល់គេឈរមើលសិន គេថា អ៊ំៗមកនេះ គេថាអ៊ំអើយ គេថា ស្រុកខ្មែរព្រំដែនមានទាំងពីច្បាប់ជាតិនិងអន្តរជាតិ ផែនទីធ្វើតាំងពីឆ្នាំប៉ុន្មាន? គេប្រាប់? គេថា យើងឆ្ការៗ ធ្វើតាំងពីដូនតាមើលរឿងដីធ្លីស្អីៗ មិនដឹងជារបស់គេ និងជារបស់យើង ឥលូវយើងមានផែនទី។ គេមកពន្លត់កំហឹងពួកខ្ញុំ ។ ដីនេះ ពួកខ្ញុំធ្វើតាំងពីដូនតាមក ពួកខ្ញុំមិនដឹង ផែនទីត្រឹមណាទេ? ភូមិអំផុល និងភូមិធ្លក សុទ្ធតែភូមិខ្មែរ មិនមែនបាត់តាំងពីដូនតាមកទេ បាត់សម័យខ្ញុំទេ។ គាត់ថា ភូមិខ្មែរចូលដីវៀតណាមខ្ញុំ បើមានកាំភ្លើង ចង់បាញ់ទូរទស្សន៍ហ្នឹងចោល គាត់ថា ពលរដ្ឋចូលដីវៀតណាម ឱ្យលោកឯងរៀនមួយសារទៀត»។

វិទ្យុអាស៊ីសេរី មិនទាន់អាចទាក់ទងសុំការបកស្រាយបន្ថែមរឿងនេះពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការកិច្ចការព្រំដែន លោក ឡាំ ជា បាននៅឡើយទេ នៅថ្ងៃទី ៣០ សីហា ដោយទូរស័ព្ទហៅចូល តែគ្មានអ្នកលើក។

កាលពីខែកក្កដាកន្លងទៅគណៈកម្មាធិការចម្រុះកិច្ចការព្រំដែននៃទីស្តីការគណៈរដ្ឋមន្ត្រីបានចេញសេចក្តីប្រកាសព័ត៌មានមួយបង្ហាញថា ការបោះបង្គោលព្រំដែនរវាងកម្ពុជានឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមការដឹកនាំរបស់លោក




ពណ៌ក្រហម ខេត្តត្បូងឃ្មុំ

នាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើឡើងត្រឹមត្រូវ ម៉ត់ចត់ និងច្បាស់លាស់ ដើម្បីរក្សាបានផ្ទៃក្រឡាដីកម្ពុជា ១៨១ ០៣៥ ដូចបានកំណត់ច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ។

អតីតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ លោក អ៊ុំ សំអាន ពន្យល់ថា រដ្ឋាភិបាលបោះបង្គោលព្រំដែន ជាមួយវៀតណាមដោយមិនផ្អែកតាមមរតករបស់បារាំង ឬអនុសញ្ញាកម្ពុជាកូសាំងស៊ីន ឆ្នាំ១៨៧៣ នឹងធ្វើឱ្យដីស្រែ និងភូមិខ្មែរមួយចំនួនបាត់បង់ទៅវៀតណាមជាបន្តបន្ទាប់។

**តទៅទំព័រទី២៣**

# After Border Post Demarcation Tbong Khmum Residents Claim...

From Page 17

some Khmer border posts were occupied by Vietnam.

Citizens asked to remain anonymous say: “It is very difficult to set up a border post, they just point it out and show it. Most people do not know, they conspire, they go and talk to each other. "People do not know until the next day to see the pillars, some are crying, and some do not dare to speak.”

Another resident of Chanmoul village, Chin Chhorn, said his family owned a total of seven hectares of farmland, but when authorities demarcated a border post and a belt road, only one hectare remained, leaving another six hectares under Vietnamese control.

“I am in so much pain and I am still sad. How can it be obvious that if the future of the next generation can be resolved from generation to generation according to international law, I am also happy,” Chin Chhorn said.

In Trapeang Phlong village, Ponhea Krek district, 106 families have been in land disputes for many years, after the Cambodian and Vietnamese governments demarcated border posts 114 to 119, causing them to lose more than 60 hectares of ancestral farmland.

Image of border post 7 in Memot district, Tbong Khmum province on September 2, 2023.
Photo by: Citizens

Villagers claim that Vietnamese soldiers often carry guns, batons, and handcuffs across the border to evict and move their huts, claiming it is border area land.

The youth who regularly inspect the border area, Mr. Soeun Makara, asked the new government to speed up the resolution for this issue to the people fairly and allow the youth to participate in monitoring this issue widely.

Mr. Soeun Makara: “The new government needs to have a mechanism to eliminate doubts and show confidence to their citizens. "There must be a clear mechanism to motivate the people themselves to stand up for their territorial integrity.”

RFA could not immediately reach for comment from the minister in charge of Border Affairs Lam Chea on October 1.

The new head of the government spokesman, Pen Bona, could not be reached for comment the same day.

But in the issues Prime Minister Hun Sen has warned to arrest anyone who criticizes the border issue.

Mr. Hun Sen: “Now, arrest them all, no one mess up with the border issue. “don’t say that Hun Sen government is dictatorial, it is not advocacy.

Recently, the Minister in charge of the Secretariat of State for Border Affairs, Lam Chea, issued a press release claiming that the demarcation of the border between Cambodia and the Socialist Republic of Vietnam was in accordance with the principles of law and international law as stated in the 2005 Adding Treaty is done correctly, clearly and provides great benefits to the people.

Former CNRP lawmaker Oum Sam An says that in the past, Hun Sen's one-party government has demarcated border posts, a lack of transparency and many irregularities, resulting in the loss of Cambodian land along the border.

**Please see /23**

តមកពីទំព័រទី ១៦

## ក្រោយបោះបង្គោលជាមួយវៀតណាម

សុំការបកស្រាយបន្ថែមរឿងនេះពីរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការកិច្ចការព្រំដែន លោក ឡាំ ជា បាននៅឡើយទេ នៅថ្ងៃទី១ តុលា។

រីឯប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលដែលទើបឡើងកាន់តំណែងថ្មី លោក ប៉ែន បូណា ក៏មិនទាន់អាចទាក់ទងបានដែរ នៅថ្ងៃដដែលនេះ ដោយទូរស័ព្ទហៅចូល តែគ្មានអ្នកលើក។

ក៏ប៉ុន្តែ កន្លងទៅ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានចាប់ខ្លួនជនទាំងឡាយណា ដែលរិះគន់ពីបញ្ហាព្រំដែន។

លោក ហ៊ុន សែន៖ «ឥលូវមកប៉ុន្មានចាប់ប៉ុណ្ណឹង រឿងទល់ដែនអត់មានឱ្យរញ៉េរញ៉ៃ។ កុំថា រដ្ឋាភិបាលហ៊ុន សែន ផ្ដាច់ការ នេះមិនមែនការតស៊ូមតិទេ»។

ថ្មីៗនេះ រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន ដែលទើបឡើងកាន់តំណែង លោក ឡាំ ជា បានចេញលិខិតប្រកាសព័ត៌មានមួយ អះអាងថា ការបោះបង្គោលព្រំដែនរវាងកម្ពុជានឹងសាធារណរដ្ឋសង្គមនិយមវៀតណាមគឺអនុវត្តតាមគោលការណ៍ច្បាប់ និងអន្តរជាតិ ដូចមានចែង ក្នុងសន្និសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ធ្វើឡើងត្រឹមត្រូវ ច្បាស់លាស់ និងផ្ដល់ប្រយោជន៍ធំធេងដល់ពលរដ្ឋ។

អតីតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ លោក អ៊ុំ សំអាន មានប្រសាសន៍ថា កន្លងទៅ រដ្ឋាភិបាលឯកបក្ស របស់លោក ហ៊ុន សែន បានកំណត់បង្គោលព្រំដែនដោយលាក់បាំង ខ្វះតម្លាភាព និងមានភាពមិនប្រក្រតីច្រើន ធ្វើឱ្យបាត់បង់ដីខ្មែរតាមតំបន់ព្រំដែន។

លោក អ៊ុំ សំអាន៖ «ពលរដ្ឋសឹងមិនហ៊ានចេញពីផ្ទះផង នៅសម័យកូវីដ១៩ ជាឱកាសរដ្ឋាភិបាល លោក ហ៊ុន សែន បោះបង្គោលលួចលាក់ចោរលួច។ រដ្ឋាភិបាលថ្មី គួរបង្ហាញស្នាដៃ អ្វីដែលឪពុករបស់ខ្លួនធ្វើខុសគឺកែ កុំឱ្យជាប់ឈ្មោះជាជនក្បត់ជាតិ ដូចពលរដ្ឋថា ពីឪហើយមកដល់កូនទៀត»។

អនុសញ្ញាទីក្រុងវីយែន ប្រទេសអូទ្រីស (Austria)ឆ្នាំ ១៩៦៩ ស្ដីពីសន្និសញ្ញា ចែងថា ការបោះបង្គោលព្រំដែនត្រូវអនុលោមតាមប្រទេសដាក់អាណានិគមដែលកម្ពុជាធ្លាប់ឋិតក្រោមអាណានិគមនិយមបារាំង។

លោក អ៊ុំ សំអាន អះអាងថា មរតកបន្សល់ពីសម័យបារាំងគឺជាអនុសញ្ញាកម្ពុជាកូសាំងស៊ីនឆ្នាំ ១៨៧៣ ដែលមានបង្គោលព្រំដែន ១២៤ បង្គោល ដែលរដ្ឋាភិបាលអាណត្តិថ្មី ត្រូវស្វែងរកបង្គោលទាំងនេះ ធ្វើជាមូលដ្ឋានកំណត់ព្រំដែន។

រីឯ កិច្ចព្រមព្រៀងសន្តិភាព ក្រុងប៉ារីស ឆ្នាំ១៩៩១ បានចែងថា រដ្ឋាភិបាលវៀតណាមបានចុះហត្ថលេខា ដោយសន្យាថា ឈប់ឈ្លានទឹកដីកម្ពុជា។

កាលពីឆ្នាំ២០២០ គណៈកម្មាធិការចម្រុះកិច្ចការព្រំដែននៃទីស្ដីការគណៈរដ្ឋមន្ត្រីកម្ពុជា និងវៀតណាម បានចុះហត្ថលេខាប្រើប្រាស់ផែនទីថ្មី ខ្នាត ១/២៥ពាន់ យកពីប្រទេសវៀតណាម និងបោះពុម្ព ដោយក្រុមហ៊ុនឯកជនមួយនៅប្រទេសដាណឺម៉ាក (Denmark)។

រដ្ឋាភិបាលចាត់ទុកការប្រើផែនទីថ្មីនេះ គឺជាការទទួលស្គាល់លទ្ធផលបង្គោលព្រំដែនកម្ពុជា និងវៀតណាម ដែលបោះរួចចំនួន ៨៤ភាគរយ។

ចំណែកគណបក្សប្រឆាំងនិងមន្ត្រីសង្គមស៊ីវិលចោទថា ការចុះហត្ថលេខាទទួលយកផែនទីនេះជាការទទួលស្គាល់ការឈ្លានពានរបស់វៀតណាម ខណៈដែលកម្ពុជាកំពុងមានជម្លោះនយោបាយដឹកនាំដោយរដ្ឋាភិបាលឯកបក្ស ឡើងកាន់អំណាចដោយសារការបោះឆ្នោតបង្គ្រប់កិច្ចចំនួន ២អាណត្តិមកហើយ៕

តមកពីទំព័រទី ២២

## ពលរដ្ឋខេត្តត្បូងឃ្មុំស្នើរដ្ឋាភិបាល

លោក អ៊ុំ សំអាន៖ «អ្វីដែលបោះបង្គោលកន្លងមក មិនត្រឹមត្រូវគួរតែសើរើឡើងវិញ។ ភូមិខ្មែរ និងផ្ទះខ្មែរ ចូលដីយួន លេខាធិការដ្ឋានគណៈកម្មការព្រំដែន គួរតែពិនិត្យមើលឡើងវិញ។ បើដោះស្រាយមិនចេញគួរតែប្ដឹងទៅតុលាការ យុត្តិធម៌អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាហ្នឹងបាន»។

ទាក់ទិនបញ្ហានេះ ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា នៅប្រទេសន័រវែស (Norway) លោក ម៉ែន ណាត ស្នើលោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត គួរតែដោះស្រាយបញ្ហានេះ និងទុក្ខកង្វល់រួមរបស់ពលរដ្ឋ ដើម្បីលាងជម្រះកម្អែលប្រវត្តិសាស្ត្រដែលបន្សល់ពីឪពុករបស់លោក។

លោក ម៉ែន ណាត៖ «ការបោះបង្គោលព្រំដែន ធ្វើឡើងដោយរដ្ឋាភិបាលហ៊ុន សែន កន្លងហើយ យកសន្ធិសញ្ញាឆ្នាំ១៩៨៥ ជាមូលដ្ឋានរួមទាំងធ្វើផែនទីថ្មីៗ មិនត្រឹមត្រូវ តាមផែនទីដើម ចែងក្នុងមាត្រា ២ នៃរដ្ឋធម្មនុញ្ញ។ តាមច្បាប់ត្រូវសើរើឡើងវិញ។ នាយករដ្ឋមន្ត្រីក៏ដោយ ត្រូវមានទោស ស្មើនឹងទោសប្រហារ ឬទោសក្បត់ជាតិ»។

កាលពីខែវិច្ឆិកា ឆ្នាំ២០១៩ លោក ហ៊ុន សែន បានទៅចុះហត្ថលេខាទទួលស្គាល់បង្គោលព្រំដែន ដែលបានបោះរួចចំនួន៨៤%ជាមួយភាគីវៀតណាម ដល់រដ្ឋធានីហាណូយ។



បើទោះជាគណបក្សប្រឆាំង ចាត់ទុកការបោះបង្គោលព្រំដែនកន្លងទៅ មិនស្របតាមមរតកបន្សល់ទុកពីអាណានិគមនិយមបារាំង និង ផ្ទុយពីកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញកម្ពុជា៕

# After Border Post Demarcation Tbong Khmum Residents Claim...

From Page 22

Mr. Oum Sam An: “People almost did not dare to leave their homes during the Covid-19 pandemic, as an opportunity for the Hun Sen government to set up a secret burglary post.” The new government should show what his father did wrong, not to be labeled a traitor (like the people say) from father to son."

The 1969 Treaty of Vienna, Austria states that the demarcation of the border must be in accordance with the colonies of which Cambodia was once a French colony.

Mr. Oum Sam An claimed that the legacy of the French period was the 1873 Cambodia-Cochinchina Convention, which had 124 border posts, which the new government had to find these posts/ demarcation as a border basis.

The 1991 Paris Peace Accords stated that the Vietnamese government had signed a pledge to stop invading Cambodian territory.

In 2020, the Joint Committee on Border Affairs of the Office of the Council of Ministers of Cambodia and Vietnam signed a new 1 / 25,000 scale map from Vietnam and published by a private company in Denmark.

The government considers the use of the new map to be a recognition of the results of the Cambodia-Vietnam border post, which was posted by 84 percent.

Opposition parties and civil society officials allege that the signing of the map acknowledges Vietnam's aggression as Cambodia is embroiled in a political conflict led by a one-party government that has been in power for two terms.

**PRINT READERSHIP**
*50,000 Monthly / 600,000 Annually*
*Plus additional exposure in our online editions at khmerpostusa.com*

KhmerPost USA

**ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM**

# 2023 PRINTING SCHEDULES

## EFFECTIVE JANUARY 1, 2023

## ADVERTISING RATES AND SIZES

*All ads are printed in Full Color*

**Ad Size (WxH)**

| | |
|---|---|
| **Full Inside** (10” wide x 13” tall) | $ 552.00 |
| **1/2** (10” wide x 6.5” tall) | 375.00 |
| **1/4** (5” wide x 6.5” tall) | 192.00 |
| **1/8** (5” wide x 3.25” tall) | 108.00 |
| **Business Card** (3.5” wide x 2” tall) | 60.00 |
| **Full Back Page** (10” wide x 13” tall) | $ 1000.00 |
| **Front Page 1/2** (10” wide x 6.5” tall) | 1000.00 |
| **Front Page 1/4** (5” wide x 6.5” tall) | 620.00 |
| **Front Page 1/8** (5” wide x 3.25” tall) | 350.00 |
| **Front Page Business Card** (3.5” wide x 2” tall) | 200.00 |

Your ad is also published in our online editions of the newspaper at khmerpostusa.com




## 2023 PRINTING DATES

***Advertising deadlines are 5 business days prior to printing date.***

| | | | | | |
|---|---|---|---|---|---|
| January | 1 | Sunday | July | 1 | Saturday |
| February | 1 | Wednesday | August | 1 | Tuesday |
| March | 1 | Wednesday | September | 1 | Friday |
| April | 1 | Saturday | October | 1 | Sunday |
| May | 1 | Monday | November | 1 | Wednesday |
| June | 1 | Thursday | December | 1 | Friday |

## MONTHLY DISTRIBUTION

*70+ Locations in Lowell, MA • 7,000 copies*
*25 Locations in Lynn & Revere, MA • 1,000 copies*
*25 Locations in Providence & Cranston, RI • 2,000 copies*
*Additional distribution online*

## CONTACT INFO

**Khmer Post USA • P.O. Box 8848 • Lowell, MA 01853**
**Tel: 978.677.7163 • Fax: 978.677.7092**
**Email: khmerpostusa@gmail.com**
**www.khmerpostusa.com**

*Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau*

***Khmer Post USA Distribution Locations Include:***

*Households • Markets • Retail Businesses*
*Restaurants • Office Buildings • Government Offices*
*Chamber of Commerce • Buddhist Temple*
*Laundromats • And Much More*

Follow us @KhmerPostUSA

Subscribe @KhmerPostUSA

Follow us @KhmerPostUSA